# បរិស្ថាន ការចិញ្ចឹមជីវិត និងស្ថាប័នមូលដ្ឋានៈ វិមជ្ឈការនៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍ដីគោក

## សេចក្តីសង្ខេប*

Mairi Dupar, Nathan Badenoch, Dang Thanh Ha, Hoang Huu Cai, Le Van An, Nguyen Quang Dung, Pham Thi Huong, Sith Sam Ath, Tran Duc Vien, Zuo Ting

## I. សេចក្តីផ្តើម

បណ្តាសង្គមនៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍ដីគោក(វៀតណាម ឡាវ កម្ពុជា ថៃនិងខេត្តយុនណានរបស់ចិន)[១] មានតំបន់ភូមិសាស្រ្តរួមគ្នាមួយដែលកំពុងស្ថិតក្នុងសម្ពាធដ៏តានតឹងពីការបំលាស់ប្តូរប្រជាសាស្រ្ត អត្ថិភាពនៃការអភិវឌ្ឍន៍តាមបែបតំបន់ទំនាបកណ្តាលនិងគំរោងការនៃការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធថ្នាក់តំបន់។ គោលនយោបាយនានាក្នុងការអភិរក្សតំបន់ជីវសាស្រ្តចំរុះនៃតំបន់ខ្ពង់រាប កិច្ចការពារព្រៃឈើដែលនៅសេសសល់ ការស្តារព្រៃឈើនៅតំបន់ភ្នំដែលរលីងស្អាតនោះគឺសុទ្ធតែទទួលការបរាជ័យនិងបានបង្អាក់ដំណើរការទូទាំងតំបន់នូវឧស្ម័នកាបោន និង ទឹក និងសេវ៉ាកម្មផ្សេងៗទៀតដែលផ្តល់ដោយប្រព័ន្ធអេកូឡូស៊ីដ៏ស្រស់ស្អាត។ កត្តាអស់ទាំងនោះបានធ្វើអោយប្រជាជននៅក្នុងតំបន់ខ្ពង់រាបទាំងឡាយកាន់តែក្រីក្រឡើងថែមមួយកំរិតទៀត។

ជាផ្នែកៗ កិច្ចប្រឹងប្រែងនានាក្នុងការអភិរក្សនោះគឺពុំទាន់មានលក្ខណៈសមល្មមដើម្បីប្រឈមមុខជាមួយនិងសម្ពាធនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចបាននៅឡើយទេ។ ប៉ុន្តែគោលនយោបាយនៃការការពារបរិស្ថាននិងគោលនយោបាយនៃការអភិវឌ្ឍន៍ជនបទបានខកខានផងដែរក្នុងការភ្ជាប់ខ្លួនជាមួយនិងទំនុកចិត្តនិងការប្រណិបត្តិតាមរបស់ប្រជាជនក្នុងមូលដ្ឋានដែលជាអ្នកយល់ឃើញថាបញ្ហាទាំងឡាយពីថ្នាក់លើតែងតែផ្ទុយពីផលប្រយោជន៍របស់ខ្លួន។ និន្នាការបច្ចុប្បន្នក្នុងបញ្ហានយោ

---

* របាយការណ៍នេះគឺជាសេចក្តីសង្ខេបពីអត្ថបទរបស់ Dupar, Badenoch et al., *បរិស្ថាន ការចិញ្ចឹមជីវិតនិងស្ថាប័នមូលដ្ឋានៈ វិមជ្ឈការនៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍ដីគោក។ ទីក្រុងវ៉ាស៊ីនតោន DC: វិទ្យាស្ថានធនធានពិភពលោក ២០០២។* *ISBN No. 1-56973-506-9.*

បាយសេដ្ឋកិច្ចនៅក្នុងតំបន់គឺរួមបញ្ចូលនូវការខិតទៅរកការធ្វើសេចក្តីសំរេចចិត្ត បែបទំរង់វិមជ្ឈការនិងការគ្រប់គ្រងទៅលើធនធានធម្មជាតិ។ តើនយោបាយអស់ទាំងនេះអាចផ្លាស់ប្តូរការសន្យាអភិបាលកិច្ចដែលអាចឆ្លើយតបទៅនិងសេចក្តីត្រូវការនិងការព្រួយបារម្ភរបស់ប្រជាជនក្នុងមូលដ្ឋានបានដែរឬទេ?

ដំណើរការវិមជ្ឈការទាំងអស់នៅក្នុងថ្នាក់តំបន់ត្រូវបានប្រកាន់យកនូវទំរង់ជាច្រើនហើយត្រូវបានដឹកនាំដោយការជំរុញទឹកចិត្តផ្សេងៗគ្នា។ ការកាត់បន្ថយភាពក្រីក្រនិងនិរន្តភាពនៃបរិស្ថានគឺជាហេតុផលពីររបស់រដ្ឋាភិបាលក្នុងការធ្វើវិមជ្ឈការ។ គោលបំនងទាំងនេះជានិច្ចកាលតែងប្រកាន់យកនូវការពិចារណាពីប្រសិទ្ធិភាពរដ្ឋបាល ការកាត់បន្ថយបន្ទុកថវិការប្រចាំឆ្នាំរបស់រដ្ឋាភិបាលនានានិងការលំអោនតាមការគាបសង្កត់របស់ម្ចាស់ជំនួយ។ ឯកសារនេះជជែកវែកញែកអោយឃើញថាស្ថានភាពបច្ចុប្បន្ននៃតំបន់ខ្ពង់រាបគឺមានសារៈសំខាន់ជាទីបំផុតក្នុងបញ្ហាកំណែទំរង់វិមជ្ឈការដែលវាជួយមិនអោយមានភាពក្រីក្រនិងការសឹករិចរឹលនៃបរិស្ថានខ្លាំងឡើងថែមទៀត។

## គោលបំណង

ឯកសារនេះចងក្រងឡើងយ៉ាងសង្ខេបអំពីឥទ្ធិពលនៃដំណើរការវិមជ្ឈការក្នុងការគ្រប់គ្រងធនធានធម្មជាតិជាពិសេសនៅក្នុងតំបន់ខ្ពង់រាបប្រទេសវៀតណាម ឡាវ កម្ពុជា ថៃនិងខេត្តយុនណានប្រទេសចិននិងបានពីករណីសិក្សាចំនួន៧កន្លែង[២] ។ ឯកសារនេះបានរកឃើញផងដែរអំពីទំនាក់ទំនងរវាងការរៀបចំការផ្លាស់ប្តូរស្ថាប័ននិងដំណើរការធ្វើសេចក្តីសំរេចចិត្តនិងការអនុវត្តន៏ការគ្រប់គ្រងធនធានធម្មជាតិ។ តួយ៉ាង ដូចជាថាតើការធ្វើវិមជ្ឈការមានការកើនឡើងនូវសំលេងសហគមន៏ជាទូទៅក្នុងការធ្វើសេចក្តីសំរេចចិត្តដើម្បីគ្រប់គ្រងធនធានដែរឬទេ? តើមានជំរើសបែបណាក្នុងការអភិរក្សនិងអភិវឌ្ឍន៏ដែលធ្វើឡើងដោយស្ថាប័នមូលដ្ឋាន? តើការធ្វើវិមជ្ឈការមាន ការផ្លាស់ប្តូរការលើកទឹកចិត្តស្ថាប័ននិងបុគ្គលនិមួយៗយ៉ាងដូចម្តេចក្នុងកិច្ចការពារបរិស្ថាន?

ក្នុងការធ្វើយ៉ាងដូច្នេះ យើងបានទាញចេញនូវចំនងទាក់ទងខ្លះៗនៃការផ្លាស់ប្តូរការអនុវត្តន៏សំរាប់និរន្តភាពសង្គមនិងបរិស្ថាននៅក្នុងតំបន់ខ្ពង់រាបនានា។ ការ

រកឃើញចំនុចសំខាន់ៗគឺមានសង្ខេបនៅក្នុងប្រអប់លេខ១។ ផ្អែកលើរបកគំហើញទាំងនេះ ឯកសារបានស្នើឡើងនូវមធ្យោបាយផ្សេងៗនៅក្នុងន័យដែលរដ្ឋាភិបាលអាចយកទៅប្រើប្រាស់បានប្រសើរជាងមុននូវឱកាសទាំងឡាយនៃការធ្វើវិមជ្ឈការដើម្បី បង្កើនការគ្រប់គ្រងនៃប្រពន្ធ័អេកូឡូស៊ីនៅតំបន់ខ្ពង់រាបនិងជីវភាពរស់នៅទាំងឡាយរបស់ប្រជាជនដែលជាអ្នកពឹងផ្អែកទៅលើធនធានទាំងនោះ។ការសិក្សាប្រៀបធៀបគ្នានេះគឺមានបំណងចង់បញ្ជាក់ដល់អ្នកធ្វើច្បាប់ថ្នាក់ជាតិថ្នាក់តំបន់និងអន្តរជាតិ(ដោយរួមបញ្ចូលផងដែរនូវអ្នកផ្តល់ជំនួយនានា)ក្នុងការធ្វើផែនការនិងការគាំទ្រអោយមានកំណែទំរង់បន្ថែមទៀត។

**ប្រអប់លេខ១: សេចក្តីសង្ខេបនៃការស្រាវជ្រាវ**

តើកំណែទំរង់វិមជ្ឈការអាចបង្ហាញនូវការជំរុញអោយមានសុវត្ថិភាពផ្នែកជីវភាពរស់នៅ ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តភាពនិងមានសមភាពសង្គមបានដោយរបៀបណា?

**ការចិញ្ចឹមជីវិត**

និយាយដោយទូលំទូលាយ កំនែទំរង់ទាំងឡាយអាចបង្កើននូវការទទួលខុសត្រូវរបស់អាជ្ញាធរក្នុងស្រុកចំពោះប្រជាជនមូលដ្ឋានដោយបង្ហាញនូវទស្ស-នីយភាពដ៏ប្រពៃសំរាប់ជំរុញជីវភាពរស់នៅទាំងឡាយរបស់ប្រជាជនក្នុងមូល-ដ្ឋាន។ វាមានន័យសំរាប់ចងភ្ជាប់រដ្ឋាភិបាលក្នុងស្រុកអោយទទួលខុសត្រូវដោយរួមទាំងការបោះឆ្នោតនិងការពិគ្រោះយោបល់ជាសាធារណៈផងដែរ។ការបោះឆ្នោតទាំងឡាយបើពួកគេមានភាពសេរីនិងភាពត្រឹមត្រូវវាអាចផ្តល់នូវមធ្យោបាយផ្ទាល់ដើម្បីជ្រើសរើសមេដឹកនាំនានាអោយធ្វើនូវអ្វីដែលជាប្រយោជន៏សាធារណៈ។ ការពិគ្រោះយោបល់ទាំងឡាយគឺមានសារៈសំខាន់ខ្លាំងណាស់ព្រោះវាអាចជួយសំរួចនូវការធ្វើផែនការនិងការអនុវត្តន៏ផែនការអភិវឌ្ឍន៏ជាក់លាក់ណាមួយ។ ទោះបីជាមានកន្លែងខ្វះដំណើរការវិមជ្ឈការនៅមានកំរិតនៅឡើយក្នុងការធ្វើវិមជ្ឈការរដ្ឋបាលប៉ុន្តែការពិគ្រោះយោបល់នានាអាចពង្រឹងនូវការធ្វើអន្តរាគមន៏របស់រដ្ឋាភិបាលអោយកាន់តែសមស្រប

ទៅតាមតំរូវការរបស់អ្នកស្រុក។ ការទទួលខុសត្រូវរបស់អាជ្ញាធរក៏បានប្រសើរជាងមុនផងដែរនៅពេលដែលគេរួមចំនែកក្នុងខ្សែរយៈសង្គមនិងបណ្តាញទាំងឡាយជាមួយសមាជិកនានា--ជួនកាលគេអាចនិយាយថាវាជា“ធនធានសង្គម”។

អាជ្ញាធរក្នុងស្រុកគឺជាអ្នកដែលមានលទ្ធភាពខ្ពស់ក្នុងការឆ្លើយតបទៅលើការព្រួយបារម្ភទាំងឡាយអំពីជីវភាពសហគមន៍នៅពេលដែលពួកគេមានធនធានគ្រប់គ្រាន់នៅក្នុងដៃ។ វាមិនមែនជាការងាយស្រួលប៉ុន្មានទេទូវបញ្ហាថវិការនោះ ប៉ុន្តែវាជាការដែលអាចមានសិទ្ធិឈោងចាប់បាននូវធនធានធម្មជាតិ។ ការមានកម្មសិទ្ធិជារៀងរហូតនិងច្បាស់លាស់នៅក្នុងក៏រិតគ្រួសារនិងសហគមន៍បានផ្តល់មូលដ្ឋានគ្រឹះសំរាប់សុវត្ថិភាពជីវភាពនៅពេលណាដែលផែនការធ្វើវិមជ្ឈការបានចូលជាធរមាន។

## បរិស្ថាន

វិធានការកែទំរង់តែមួយបែប(ការបង្កើតអាជ្ញាធរមូលដ្ឋានទាំងឡាយតាមរយៈការបោះឆ្នោតប្រជាធិបតេយ្យនិងការអនុវត្តន៍ដំណើរការពិគ្រោះយោបល់)បានជួយពង្រឹងមធ្យោបាយរបស់ប្រជាជនមូលដ្ឋានក្នុងការគ្រប់គ្រងបរិស្ថាន។ ប៉ុន្តែយើងបានរកឃើញថាបញ្ហាបរិស្ថានគឺវាទាមទារនូវការថ្លឹងថ្លែងដ៏សាំញ៉ាំមួយ។

កំណែទំរង់វិមជ្ឈការខ្លះបានសិក្សាដោយបានមរតកពីការទទួលខុសត្រូវធ្វើផែនការអភិវឌ្ឍន៍សំរាប់ថ្នាក់ភូមិឬឃុំដែលប្រមូលផ្តុំដោយមុខព្រួញជាច្រើននៃតំរូវការរបស់សហគមន៍។ ការបង្កើតអាជ្ញាធរមូលដ្ឋានដែលអាចទទួលខុសត្រូវចំពោះប្រជាជនក្នុងស្រុកពុំអាចធានាបានថាការគ្រប់គ្រងបរិស្ថានជាអត្ថិភាពកំពូលនៅក្នុងផែនការមូលដ្ឋាននោះទេ។ ប្រសិនបើប្រជាជនក្នុងសហគមន៍បានពិចារណាការព្រួយបារម្ភអំពីកិច្ចការពារបរិស្ថាននិងជីវភាពរស់នៅរបស់ពួកគេទៅក្នុងផែនការនោះ ពួកគេគួរតែធ្វើការងារជាមួយអាជ្ញាធរក្នុងមូលដ្ឋានឆ្ពោះទៅរកការរៀបចំទាំងឡាយដែលឈ្នះ-ឈ្នះ។ តួយ៉ាងក្នុងករណីខ្លះប្រជាជននៅមូលដ្ឋានបានមើលឃើញថាសហគមន៍ព្រៃឈើគឺជាប្រភព-

ចំណូលមួយសំរាប់បំពេញសេចក្តីត្រូវការបន្ទាប់បន្សំក៏ដូចជាការបង្កើនប្រាក់ចំនូលនិងបន្ថយបាននូវគ្រោះថ្នាក់ផ្សេងៗ។ ប៉ុន្តែនៅករណីខ្លះទៀតអ្នកស្រុកបានអំពាវនាវសុំអោយអាជ្ញាធរក្នុងស្រុករបស់ពួកគេធ្វើអត្ថិភាពទៅលើគំរោងហេដ្ឋារចនាសម្ពន្ធ័និងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាជាងការការពារធនធានធម្ម-ជាតិទៅវិញ។

នៅពេលដែលបានសិក្សាគោលនយោបាយវិមជ្ឈការតែទៅលើផ្នែកធម្មជាតិ(ដូចជាផ្នែកព្រៃឈើជាដើម)ការផ្សាភ្ជាប់គ្នារវាងអភិបាលកិច្ចល្អនិងលទ្ធ-ផលបរិស្ថានល្អគឺមានលក្ខណៈច្បាស់លាស់ជាងមុន។ ប្រសិទ្ធិភាពផ្នែកគោលនយោបាយគឺមានការកើនឡើងយ៉ាងធំសំបើមនៅពេលដែលអាជ្ញាធរក្នុងស្រុកមានការទទួលខុសត្រូវនិងដើរតាមការអនុវត្តន៍ដោយមានតំលាភាព។

ភាពខ្លាំងនៃគោលការណ៍បរិស្ថានថ្នាក់ជាតិនិងក៏រិតរដ្ឋាភិបាលមូលដ្ឋាននិងការប្រណិបត្តិតាមនៃសហគមន៍ចំពោះគោលការណ៍នោះបានធ្វើអោយនិរន្តភាពបរិស្ថានមានភាពល្អប្រសើរ។

នៅពេលដែលរដ្ឋាភិបាលមជ្ឈឹមអនុវត្តន៍ក៏រិតស្តង់ដារជាតិដោយធូរលុងនោះជូនកាលអាជ្ញាធរក្នុងស្រុកត្រូវកាត់នូវប្រាក់ចំនូលពន្ធអាករជាថ្នូរនិងការចំណាយផ្នែកបរិស្ថាន។ ផ្ទុយមកវិញ នៅពេលដែលរដ្ឋាភិបាលមជ្ឈឹមដាក់ចេញនូវគោលការណ៍ច្បាស់លាស់សំរាប់ការគ្រប់គ្រងបរិស្ថានដូចជាការដាំដើមឈើជាដើម-គឺជាការដាក់កំហិតជ្រុលពេក ព្រោះគោលការណ៍នេះបានបង្ខំអោយរដ្ឋាភិបាលក្នុងស្រុកអនុវត្តន៍ដោយពុំបានត្រឹមត្រូវស្របតាមតំរូវការរបស់សហគមន៍និងលក្ខណ្ឌ៍អេកូឡូស៊ីនៅទីនោះ។

ការសិក្សាបានបង្ហាញថាកំនែទំរង់វិមជ្ឈការទាំងឡាយនាំអោយមានការប្រថុយប្រថាននៃការផ្តល់អំណាចដល់អាជ្ញាធរដែនដីដោយគ្មានការពង្រឹងគ្រប់គ្រាន់នូវស្ថាបន័កណ្តាលដែលមានសារៈសំខាន់សំរាប់ការគ្រប់គ្រងដែលមានលក្ខណៈជាប្រពន្ធ័អេកូឡូស៊ី(ដូចជាអាជ្ញាធរនៃអាងទន្លេឬបណ្តាញទីជំរាលរងទឹកភ្លៀងទាំងឡាយ)។ ការគ្រប់គ្រងបរិស្ថានរបស់អាជ្ញាធរដែនដី(ពីការកាប់ឈើហ៊ុបទៅផែនការប្រើប្រាស់ដីធ្លីនិងទៅការគ្រប់គ្រងការបំពុល)វាត្រូវតែមានការសំរបសំរួលជាមួយនិងយុត្តាធិការក្បែរខាងនានានិងជាមួយស្ថាប័ន-

កណ្តាលនានា។

ស្ថាប័នសំរាប់ដោះស្រាយជំលោះបរិស្ថានគឺមានភាពទន់ខ្សោយឬខកខានស្ទើតែរាល់ករណីសិក្សានានាដោយបានលើកឡើងថាកំនែទំរង់វិមជ្ឈការទាំង-ឡាយបានបរាជ័យក្នុងការដោះស្រាយអោយបានគ្រប់គ្រាន់លម្មនូវបញ្ហាក្តៅគគុកនៃការគ្រប់គ្រងបរិស្ថាន។ កំនែទំរង់ជាច្រើនបានពង្រឹងព្រមគ្នាដល់ការទទួលខុសត្រូវផ្នែករដ្ឋបាលរបស់អាជ្ញាធរដែនដីក្នុងការគ្រប់គ្រងបរិស្ថាននិងសំរាប់ដោះស្រាយជំលោះបរិស្ថាននានា។ ដូច្នេះហើយវាអាចបង្កើតអោយមានទំនាស់ផ្នែកខាងផលប្រយោជន៍ផ្សេងៗ។

**សមភាព**

ការសិក្សារបស់យើងពុំបានបង្ហាញអោយឃើញអំពីកំនែទំរង់គោលនយោបាយនិងស្ថាបន័ដែលអាចផ្លាស់ប្តូរភាពក្រីក្រជាទូទៅឬអាចមានសិទ្ធិចូលទៅប្រើប្រាស់បាននូវធនធានធម្មជាតិដោយសហគមន៏នោះទេ។ ទោះជាយ៉ាងនេះក៏ដោយករណីសិក្សាទាំងឡាយបានបង្ហាញអោយឃើញពីមធ្យោបាយនានាដែលក្នុងនោះការធ្វើកំនែទំរង់វិមជ្ឈការអាចរៀបជាប្លង់បានដើម្បីផ្តល់នូវអំណាចដល់ក្រុមដែលងាយរងគ្រោះ(ដូចជាក្រុមស្ត្រី)អោយមានសិទ្ធិនិយាយកាន់តែច្រើនជាងមុននៅក្នុងដំណើការធ្វើផែនការជាផ្លូវការ។

ការធ្វើអន្តរាគមន៏នានាអោយចំទិសដៅគឺជាការជួយដ៏ប្រសើរដើម្បីជំនះទៅលើការលំអៀងនានា។ ជាក់ស្តែងកម្មវិធីទាំងឡាយដែលដៅកន្លែងទុកសំរាប់ស្ត្រីក្នុងជួរគណកម្មការនានានិងការផ្តល់ការអប់រំក្រៅប្រពន្ធ័ដើម្បីលើកកំពស់សមត្ថភាពនិងការជឿជាក់របស់ស្ត្រីនោះគឺបានបង្កើនអោយស្ត្រីមានសិទ្ធិនិយាយកាន់តែប្រសើរឡើងនៅក្នុងការធ្វើសេចក្តីសំរេចចិត្តថ្នាក់មូលដ្ឋាន។ ក្រុមពិភាក្សាដែលមានសុទ្ធតែស្ត្រីនោះក៏បានលើកទឹកចិត្តស្ត្រីក្នុងការបញ្ចេញមតិយោបល់ជាសាធារណៈបានល្អជាងមុនដែរ។ ជាលទ្ធភាពផងដែរសំរាប់វិធានការចំរុះដូចគ្នានេះអាចប្រើប្រាស់ដើម្បីជួយអោយប្រជាជនមូលដ្ឋានចេះធ្វើសេចក្តីសំរេចចិត្ត។

**ការលំបាកជាទូទៅ**

ការសិក្សារបស់យើងបានបង្ហាញអោយឃើញថាសំរាប់ការធ្វើវិមជ្ឈការ

ដើម្បីជំរុញអោយមានផលប្រយោជន៏ខាងជីវភាពនិងបរិស្ថាននោះវាត្រូវតែមានភាពខ្លាំង ការជួយគ្នាទៅវិញទៅមករវាងស្ថាប័នទាំងឡាយនិងមានយន្តការជាបន្តបន្ទាប់សំរាប់ភ្ជាប់ការទទួលខុសត្រូវរបស់រដ្ឋាភិបាលទៅនិងផលប្រយោជន៍សាធារណៈ។ វាគ្មានរូបមន្តណាមួយដ៏សាំមញនោះទេ។ ការធ្វើវិមជ្ឈការគឺជាការចាំបាច់បំផុតសំរាប់ដំណើរការច្រំដែលៗហើយដែលអាចប្រសើរឡើងដោយបានឆ្លងកាត់ពេលវេលាមួយដ៏វែងឆ្ងាយ។

វាមានឧបសគ្គរួមជាច្រើនក្នុងការធ្វើវិមជ្ឈការលើរាល់ករណីសិក្សានៅក្នុងបណ្តាប្រទេសអាស៊ីអាគ្នេយ៍ដីគោគ។ ឧបស័គ្គដែលពាក់ពន្ធ័ជាមួយនិងសមត្ថ-ភាពទាំងឡាយនៅក្នុងលំដាប់ថ្នាក់ផ្សេងៗគ្នា។ ជានិច្ចកាលមន្ត្រីមូលដ្ឋានទាំងនោះពុំសូវមានជំនឿចិត្តចំពោះសមត្ថភាពរបស់ពួកគេក្នុងការធ្វើអោយសំរេចបាននូវការផ្លាស់ប្តូរជាវិជ្ជមាននោះទេ។ ដូចគ្នានេះដែរប្រជាជនមូលដ្ឋានតែងតែខកខានក្នុងការឆក់យកឱកាសទាំងនោះ ព្រោះពួកគេពុំបានដឹងថាពួកគេមានសិទ្ធិឬខ្វះខាតការជឿជាក់អំពីការរួមចំនែករបស់ពួកគេក្នុងដំណើរការនៃការកសាងផែនការ។ សកម្មភាពលើកកំពស់ការយល់ដឹងនិងការអប់រំក្រៅប្រព័ន្ធដែលបានឆ្លងកាត់នៅក្នុងករណីសិក្សាមួយកន្លែងបានទទួលជោគជយ័ជាបង្គួរនៅក្នុងដំណោះស្រាយលើបញ្ហាទាំងនោះ។ តំលាភាពដែលមិនសមល្មមនិងមិនមានការបញ្ជូនពត៏មានរវាងគ្រប់លំដាប់ថ្នាក់បានធ្វើអោយយឺតនូវការអនុ-វត្តន៏គោលនយោបាយ។ ការខ្វះខាតការត្រួតពិនិត្យនិងការវាយតំលៃមានន័យថាមន្ត្រីទាំងឡាយពុំបានប្រមែប្រមូលនូវមេរៀនដ៏មានសារៈសំខាន់ដើម្បីរៀននិងជំរុញនូវសកម្មភាពសំរាប់អនាគតនោះទេ។

នៅពេលដែលបញ្ហាសមត្ថភាពបានពន្យឺតដំណើរការវិមជ្ឈការនិងធ្វើអោយខ្វះប្រសិទ្ធិភាពនោះ ពួកគេក៏បានបង្ហាញនូវឳកាសដ៏ធំធេងផងដែរ។ ជាមួយនិងភាពត្រឹមត្រូវនូវកិច្ចប្រឹងប្រែងរយៈពេលយូរអង្វែងដើម្បីអប់រំមន្ត្រីរដ្ឋាភិបាលនិងសាធារណៈនានានិងដើម្បីបង្កើនតំលាភាព ការចែកចាយពត៏មាននិងការវាយតំលៃនោះការធ្វើវិមជ្ឈការគឺហាក់ដូចជាបានបំពេញនូវសក្តានុពលរបស់ខ្លួនដើម្បីផ្តល់ជូននូវភាពត្រឹមត្រូវនិងការអភិវឌ្ឍន៏ដ៏សមស្របនៅក្នុងមូលដ្ឋាន។

## II. តើអ្វីទៅជាវិមជ្ឈការ?

កំណែទំរង់ដ៏ធំទូលាយមួយគឺបានប្រព្រឹត្តទៅនៅក្នុងប្រទេសអាស៊ីអាគ្នេយ៍ដី-គោគដែលរដ្ឋាភិបាលនានាចាត់ទុកថាជាវិមជ្ឈការនិងការធ្វើប្រជាធិបតេយ្យនីយ-កម្មនៅក្នុងមូលដ្ឋាន។ ការពិតកំនែទំរង់ទាំងនេះបានដើរតួជាសំលេងជូរតន្ត្រីដែលចេញពីភាពស្ងូន្យឈឹងទៅរកភាពភ្លឺស្អាតល្អ។ គេបញ្ចូលនូវការធ្វើវិមជ្ឈការនយោបាយ ការរៀបចំនូវសហគ្រប់គ្រងនានានិងការធ្វើវិមជ្ឈការរដ្ឋបាល។ (*សេចក្តីបកប្រែនូវសទ្ទានុក្រមសង្ខេបនៃពាក្យទាំងនេះមានភ្ជាប់ជាមួយក្នុងសេចក្តីបន្ថែមខាងក្រោយ)* ។ ភាពខុសៗគ្នារវាងទំរង់វិមជ្ឈការអាចពន្យល់បានយ៉ាងទូលំទូលាយនៅក្នុងនាមជា*អ្នកដែលមានតួនាទីទាំងឡាយ* ដែលអាចទទួលបាននូវអំណាចថ្មីហើយនៅពេលណាដែល*ទំនាក់ទំនងទំនួលខុសត្រូវទាំងឡាយ* ត្រូវបានគេបង្កើតឡើងជាផ្លែផ្កាហើយ (Agrawal និង Ribot ១៩៩៩)។ បុគ្គលនិងស្ថាបន័ទាំងអស់ត្រូវមានការទទួលខុសត្រូវនិងត្រូវឆ្លើយតបចំពោះបញ្ហាផ្សេងៗនៅពេលដែលបុគ្គលនិងស្ថាប័នទាំងនោះជាកម្មវត្ថុនៃការបង្ខំអោយប្រត្តិបតិតាមឬទទួលការដាក់ទណ្ឌកម្មនានាក្នុងការដែលខ្លួនធ្វើតួនាទីមិនបានត្រឹមត្រូវ (Brinkerhoff in Ribot, forthcoming )[៥]។ តួយ៉ាងការធ្វើវិមជ្ឈការនយោបាយគឺកំណត់លក្ខណៈដោយការបង្កើតឡើងនូវរដ្ឋាភិបាលថ្នាក់មូលដ្ឋានដែលជាបឋមនោះត្រូវមានការទទួលខុស-ត្រូវចំពោះសមាជិកទាំងឡាយនៅមូលដ្ឋានរបស់ខ្លួនតាមរយៈការបោះឆ្នោត។ វិមជ្ឈការរដ្ឋបាលគឺយោងទៅលើការផ្តល់អំណាចដល់ភ្នាក់ងាររដ្ឋាភិបាលមូលដ្ឋានទាំងអស់ដែលជាអ្នកផ្សព្វផ្សាយអោយរដ្ឋាភិបាលថ្នាក់មជ្ឈិម។ដូច្នេះហើយពួកគេជាបឋមត្រូវទទួលខុសត្រូវដល់ខ្លួនគេផ្ទាល់ផងនិងដល់ចៅហ្វាយនាយរបស់គេផង។ រីឯការរៀបចំសហគ្រប់គ្រងដែលដាក់បញ្ចូលនូវតួនាទីនានារបស់ស្ថាបន័រដ្ឋាភិបាលនិងមេដឹកនាំសហគមន៏ទាំងអស់ដែលជាបែបផែនមួយនៃការបង្កើតការទទួលខុសត្រូវចំរុះពាក់ពន្ធ័ជាមួយអ្នកដែលមានតួនាទីនានានៅក្នុងមូលដ្ឋាន។

### ការលើកទឹកចិត្តដើម្បីធ្វើវិមជ្ឈការ

ក្នុងសវត្សទ៏មុន ប្រទេសនៅក្នុងតំបន់ភូមិភាគអាស៊ីអាគ្នេយ៍ដីគោគបានមាន

ការរីករាយជាមួយនិងដំណាក់កាលនៃការអភិវឌ្ឍន៍សន្តិភាពនិងកំណើនសេដ្ឋកិច្ចដែលវាផ្ទុយគ្នាជាមួយនិងសង្គ្រាមស៊ីវិល ជំលោះអន្តរជាតិ ការចាកចោលទីលំនៅដ៏ច្រើនសន្ធឹកសន្ធាប់និងការធ្វើអន្តោប្រវេសន៍ដូចដែលមានចារឹកទុកនៅក្នុងទសវត្សទ៍ទី៥០ ៦០និង៧០ស្រាប់។ ទោះបីជាប្រទេស វៀតណាម ឡាវនិងកម្ពុជាបានជួបប្រទះនិងការវិនាសហិនហោចក្នុងអំលុងពេលនោះក៏ដោយក៏ប្រ-ទេសថៃនិងចិនឯណោះដែលជាប្រទេសពីរនៅក្នុងតំបន់បានទទួលរងគ្រោះថ្នាក់ជាយថាហេតុដោយសារតែការរំជើបរំជួលនិងចលនាប្រជាជននិងជំលោះក្នុងស្រុកនានារបស់ពួកគេ។

ជាមួយនិងការមកដល់នូវស្ថេរភាពដ៏ធំធេងក្នុងអំលុងពេល១០-២០ឆ្នាំកន្លងមកនេះ រដ្ឋាភិបាលទាំងនោះនៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍ដីគោកបានចាប់ផ្តើមនូវការធ្វើវិមជ្ឈការលើលំដាប់ថ្នាក់ផ្សេងៗគ្នានៃផ្នែកនយោបាយ រដ្ឋបាលនិងតួនាទីសារពើពន្ធទាំងឡាយនៃរដ្ឋាភិបាលថ្នាក់ក្រោមរបស់ពួកគេ។ នៅក្នុងប្រទេសចិននិងវៀតណាម សេចក្តីប្រកាសផ្នែកគោលនយោបាយទាំងឡាយបានជំរុញនូវសញ្ញាណនៃប្រជាធិបតេយ្យថ្នាក់មូលដ្ឋានដែលជាការល្អសំរាប់ខ្លួនឯងផងនិងសំ-រាប់ហេតុផលមជ្ឈឹមក្នុងការជំរុញតួនាទីរបស់អាជ្ញាធរមូលដ្ឋានផងដែរ(តួយ៉ាង ឃុំនិងស្រុក)ក្នុងការអនុវត្តន៍គោលនយោបាយនិងកំរិតផែនការអភិវឌ្ឍន៍នានា។ នៅប្រទេសចិនអ្នកដឹកនាំដ៏ធំបំផុតក្នុងការធ្វើវិមជ្ឈការប្រហែលជាមានបំនងចង់បង្កើនប្រសិទ្ធិភាពនៃសារពើពន្ធនិងកាត់បន្ថយបន្ទុកសារពើពន្ធទៅលើរដ្ឋាភិបាលមជ្ឈឹម(ដូចជា Fan ១៩៩៩)[៦]។ ដូចគ្នានេះដែរ នៅក្នុងប្រទេសវៀតណាមការរៀបចំសារពើពន្ធថ្មីបានបង្កើននិន្នាការនៃក្រសួងនានារបស់រដ្ឋាភិបាលដើម្បីបង្ខំអោយការចំណាយទាំងឡាយធ្លាក់ចុះនៅកំរិតមួយទាបជាងមុនតាមដែលអាចធ្វើទៅបាន (Rao, ១៩៩៩)។

នៅក្នុងប្រទេសវៀតណាមនិងឡាវការធ្វើវិមជ្ឈការភាគច្រើនបានកើតឡើងតែនៅក្នុងរង្វង់វិស័យណាមួយជាក់លាក់(ទឹក ព្រៃឈើនិងកសិកម្ម)ហើយបានចាប់យកនូវកំណែទំរង់នៃវិមជ្ឈការ។ នៅក្នុងន័យនេះកំណែទំរង់ដែលបានពិពណ៌នាច្បោះៗថាជាវិមជ្ឈការដែលត្រូវបានគេធ្វើបែបមជ្ឈការជាជាងវិមជ្ឈការ។

កំនែទំរង់តំណាងអោយកិច្ចប្រឹងប្រែងមួយដើម្បីពង្រឹងការគ្រប់គ្រងរដ្ឋហើយការអភិវឌ្ឍន៏ដែលកំនត់ដោយរដ្ឋដូចដែលបានចែងក្នុងវិស័យអស់ទាំងនេះគឺជាការបង្កើនការគ្រប់គ្រងរដ្ឋទៅលើជនបទដាច់ស្រយ៉ាលផងដែរ។

ការធ្វើពិសោធន៏ដ៏ធំមួយនៅក្នុងផ្នែកនយោបាយនិងការធ្វើវិមជ្ឈការសារពើពន្ធត្រូវបានប្រព្រឹត្តឡើងនៅក្នុងប្រទេសកម្ពុជា ដោយមានការបង្ហូរជំនួយយ៉ាងធំពីមជ្ឈដ្ឋាននានាដើម្បីការស្ថាបនាប្រទេសជាតិឡើងវិញ។ គំរោងសាកល្បងមួយនៅក្នុងប្រទេសកម្ពុជាសំរាប់ផែនការអភិវឌ្ឍន៏វិមជ្ឈការបានប្រព្រឹត្តទៅនៅក្នុងខេត្តដំបូងចំនួន៥និងបន្ទាប់មកចំនួន១០ខេត្តទៀត។ ក្រុមប្រឹក្សានានានៃម្ចាស់ជំនួយសំរាប់កម្ពុជាបានអនុវត្តន៏កម្មវិធីអភិវឌ្ឍន៏វិមជ្ឈការថ្នាក់ជាតិនោះគឺជាស្នូលមួយនៃការចរចាររបស់ខ្លួនជាមួយរដ្ឋាភិបាលកម្ពុជា។

ប្រទេសថៃបានចាប់ផ្តើមទៅលើកំនែទំរង់វិមជ្ឈការដ៏មហិច្ឆតារបស់ខ្លួននៅក្នុងតំបន់ នោះគឺការដែលបានធ្វើយ៉ាងពេញបន្ទុកនូវវិមជ្ឈការនយោបាយទៅលើកំរិតនៃអនុស្រុក។ ដូច្នេះហើយកំនែទំរង់ដ៏ជ្រាលជ្រៅរបស់ខ្លួនបានបង្កើតលទ្ធភាពអោយមានការដាក់បញ្ចូលព្រមៗគ្នានូវគណបក្សនយោបាយទាំងឡាយនិងផលប្រ-យោជន៏បញ្ញាសាស្ត្រ។ គណបក្សនយោបាយទាំងនោះបានគិតអំពីការពង្រឹងមូលដ្ឋានគាំទ្ររបស់ពួកគេនៅក្នុងតំបន់ជនបទទាំងឡាយដោយសារការបង្កើនសំលេងរបស់សមាជិកនានានៅក្នុងតំបន់ជនបទតាមរយៈការអភិវឌ្ឍន៏ការធ្វើសេចក្តីសំរេចចិត្តនិងការជំរុញឥស្សរជនបញ្ញាវន្ត័នានាអោយមានការទទួលខុសត្រូវយ៉ាងធំធេងក្នុងការពង្រាងភាសានៃវិមជ្ឈការនៅក្នុងរដ្ឋធម្មនុញ្ញថ្មីរបស់ពួកគេ[៨]។

នៅបណ្តាប្រទេសជាច្រើនកំនែទំរង់វិមជ្ឈការដ៏ប្រសើរជាងនេះតែងបានកើតឡើងនៅក្នុងកម្មវិធីនានានៃផែនការវិមជ្ឈការដែលផ្តល់មូលនិធិដោយអ្នកផ្តល់ជំ-នួយ ។ កម្មវិធីយ៉ាងដូច្នេះមានតែនៅក្នុងខេត្តដែលបានជ្រើសរើសមួយចំនួនប៉ុណ្ណោះ។ តួយ៉ាង ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៏អន្តរជាតិស៊ុយអែដបានមានបទពិសោធន៏ជាមួយគំរោងថវិការអភិវឌ្ឍន៏វិមជ្ឈការមួយនៅក្នុងខេត្ត៥របស់ប្រទេសវៀតណាម។ ការវាយតំលៃមួយនៃផែនការនេះបានបង្កើតឡើងនូវទំរង់មួយនៃករណីសិក្សារបស់ពួកយើង។ ការសាកល្បងនេះបានជួយអោយមានប្រតិ-

កម្មជាមួយកម្មវិធីអ្នកផ្តល់មូលនិធិផ្សេងទៀតនៅក្នុងបណ្តាខេត្តភាគខាងជើងដែលមានមហិច្ឆតាធ្វើវិមជ្ឈការថវិការនិងរចនាសម្ព័ន្ធការអនុវត្តន៍នានា[៩]។

ផែនការវិមជ្ឈការវិស័យកសិកម្មនៅក្នុងប្រទេសឡាវបានទទួលប្រយោជន៍ពីបុគ្គលិកម្ចាស់ជំនួយនិងមូលនិធិនានាយ៉ាងក្រាស់ក្រែល ជាពិសេសតាមរយៈកម្មវិធីព្រៃឈើស៊ុយអែដ-ឡាវ។ ប្រហែលជានៅពេលដែលការមិនមានបទពិសោធន៍មិនគ្រប់គ្រាន់របស់ប្រទេសឡាវនោះហើយបានជាករណីនេះបានបង្ហាញអោយឃើញពីការប៉ងប្រាថ្នារបស់ម្ចាស់មូលនិធិដើម្បីគាំទ្រនូវការព្រួយបារម្ភរបស់ប្រជាជនមូលដ្ឋាននៅក្នុងតំបន់ទាំងមូល។ ជាការពិតកម្មវិធីទាំងឡាយរបស់ម្ចាស់មូលនិធិនោះអាចបង្ហាញភស្តុតាងថាជាប្រថ្នូលល្អមួយសំរាប់អនាគត។

## III. លទ្ធផលនៃការសិក្សា

ដោយផ្អែកលើរបាយការណ៏នេះករណីសិក្សាទាំងឡាយបង្ហាញអោយឃើញកំពូលភ្នំនានានៅក្នុងប្រទេសអាស៊ីអាគ្នេយ៏ដីគោគនោះនូវទស្សនៈប្លែកៗគ្នា។ ទីមួយទីតាំងសិក្សាទាំងអស់បានប្រឈមមុខនិងការអភិវឌ្ឍន៏ដ៏ខ្ទេចខ្ទាំនិងសម្ពាធប្រជាពលរដ្ឋដែលជាហេតុនាំអោយមានការសឹករិចរិលទ្រព្យសម្បត្តិធម្មជាតិ។ ទីពីរ រាល់ទីតាំងទាំងនេះបានពាក់ពន្ធ័ជាមួយនិងក្រុមជនអន្តោគ្រាមផ្សេងៗជាមួយនិងប្រពៃណីផ្សេងៗគ្នាក្នុងការគ្រប់គ្រងធនធានធម្មជាតិ។ សេដ្ឋកិច្ចនៃទីតាំងសិក្សានេះមានការខុសប្លែកគ្នាលើបញ្ហាលក្ខណ្ឌ័នយោបាយនិងសេដ្ឋកិច្ចហើយ ការខុសគ្នា នេះប្រហែលក្លាយទៅជាការលំបាកដ៏ធំបំផុតមួយក្នុងការធ្វើការសិក្សាប្រៀបធៀបតំបន់នៃការធ្វើវិមជ្ឈការនិងថាមពលរបស់ស្ថាបន័នានា។លទ្ធផលការសិក្សាបានធ្វើសេចក្តីសង្ខេប និងបង្ហាញជូនដូចនៅក្នុងតារាងផ្តេកទាំងមូលនៃរបាយការណ៏នេះ។ ចំនែកឯបញ្ហាអធិការកិច្ចដែលលេចធ្លោពីតំបន់នោះគឺនឹងបង្ហាញអោយឃើញនៅក្នុងជំពូកក្រោយទៀត។

តារាងខាងក្រោមនេះផ្តល់នូវបរិបទផ្អែកគោលនយោបាយសំរាប់ករណីសិក្សានិមួយៗ ហើយពណ៏នាអំពីអ្នកដើរតួនាទីណាខ្លះទទួលបានអំណាចអ្វីនៅខាងក្រោមនៃកម្មវិធីការធ្វើវិមជ្ឈការនេះហើយថែមទាំងបានកត់សំគាល់នូវទំរង់វិមជ្ឈការណាខ្លះដែលបានកើតមានឡើង។

| ទីកន្លែងសិក្សា | លក្ខណៈបរិស្ថាននិងសង្គម | ការសិក្សាគោលការណ៍រួមគ្នា | ថាមភាពនៃវិមជ្ឈការ | |
|---|---|---|---|---|
| | | | អ្នកមានតួនាទីនិងអំណាច | លទ្ធផល |
| ខេត្តញៀ អាន វៀតណាម | • អត្រាដីព្រៃដែលមានការបាត់បង់យ៉ាងខ្ពស់។<br>• មានអត្រាចំរុះជនជាតិភាគតិចដ៏ខ្ពស់។<br>• មានភាពក្រីក្រយ៉ាងធ្ងន់ធ្ងរ | • គោលការណ៍ផ្តល់ដីព្រៃ។<br>• គោលការណ៍ធ្វើអោយបៃតងនៃភ្នំដែលត្រងោល | • មន្ត្រីនៃទីភ្នាក់ងាររុក្ខាស្រុកទទួលបានសិទ្ធិទទួលខុសត្រូវក្នុងការផ្តល់កម្មសិទ្ធិនិងផែនការប្រើប្រាស់ដីធ្លី។<br>• គ្រួសារនិមួយៗបានការទទួលខុសត្រូវក្នុងការដាំដើមឈើ។<br><br>ការធ្វើវិមជ្ឈការរដ្ឋបាល | • ខ្វះខាតនូវដំណើរការពិគ្រោះយោបល់ដ៏ពិតប្រាកដ កាត់បន្ថយភាពសមរម្យនិងប្រសិទ្ធិភាពនៃគោលន.ប<br>• បានពិពណ៌នានូវបច្ចេកទេសជាក់លាក់ពីថ្នាក់មជ្ឈឹមបង្កើតអោយមានលទ្ធផលមិនអនុគ្រោះសំរាប់ជីវភាពនិងបរិស្ថាន។ |
| ខេត្តភូ ថូ វៀតណាម | • ដីព្រៃរិចរឹល<br>• ការកើនឡើងនូវឱកាសសំរាប់ទីផ្សារនានា។<br>• មានអត្រាចំរុះជនជាតិភាគតិចខ្ពស់។<br>• ការរីកដាលនៃភាពក្រីក្រ | • ក្រិតថែងអំពីប្រជាធិបតេយ្យនៅមូលដ្ឋាន។<br>• ថវិការអភិវឌ្ឍន៍វិមជ្ឈការតាមរយៈគំរោងដ៏ធំរបស់ម្ចាស់មូលនិធិ: កម្មវិធីអភិ | • ក្រុមគ្រប់គ្រងភូមិដែលបានជាប់បោះឆ្នោតមានសិទ្ធិត្រួតត្រាទៅលើថវិការជាមួយនិងប្រាក់ចំនួលផ្តល់ដោយគំរោងម្ចាស់មូលនិធិ។<br>• សហគមន៍ទាំងឡាយមានការកើនឡើងនូវតួនាទីក្នុង | • គុណវិបត្តិទាំងឡាយនៅក្នុងការបោះឆ្នោតការពិគ្រោះយោបល់សហគមន៍បាននាំអោយមានការទោមនស្សជាមួយនិងផលប្រយោជន៍នៃកម្មវិធី។<br>• លំហូរពត៌មានដ៏ខ្សត់ |

| | | | | |
|---|---|---|---|---|
| | | វឌ្ឍន៍ជនបទតំ-បន់ភ្នំស៊ុយអែដ-វៀតណាម។ | ការធ្វើផែនការអភិវឌ្ឍន៍<br>• ក្រុមគ្រប់គ្រងភូមិត្រូតពិនិត្យមើលលើផែនការ។<br><br>**វិមជ្ឈការនយោបាយ** | ខ្សោយរបស់រដ្ឋភិបាលបានរារាំងប្រសិទ្ធិភាពទាំងឡាយ។<br>• អ្នកបោះឆ្នោតបានបណ្តេញចេញមន្ត្រីពុករលួយពាក់ពន្ធ័ក្នុងការកាប់ឈើខុសច្បាប់។ ឆាប់ពេកក្នុងការវិនិច្ឆ័យទៅលើកម្មវិធីអនុវត្តន៍បរិស្ថាន។ |
| **ខេត្តធូធានហូ វៀតណាម** | • តំបន់រងទឹកភ្លៀងនៅភាគខាងលើមានការបាត់បង់ (ព្រោះការបាចម្សៅគីមីអំលុងពេលសង្គ្រាម)<br>• ភាពងាយរងគ្រោះរបស់មនុស្សដោយសារទឹកជំនន់។<br>• កសិកម្មចិញ្ចឹមជីវិតជាមួយនិងជំរើសផ្នែកជីវភាពដ៏ស្តួចស្តើង។ | • មានក្រិត្យច្បាប់អំពីប្រជាធិបតេយ្យថ្នាក់មូលដ្ឋាន<br>• មាន១៣៥កម្មវិធីសំរាប់ផ្តល់ជំនួយដល់សហគមន៍ដែលក្របំផុត។ | • អាជ្ញាធរឃុំទទួលជំនួយថ្មីបែងចែកពីរដ្ឋាភិបាលមជ្ឈឹម និង មានការប្រុងប្រយ័ត្នក្នុងការចំណាយមូលនិធិនិងថវិការ។<br>• គណកម្មការគ្រប់គ្រងតំបន់ទីជំរាលទឹកភ្លៀងរបស់រដ្ឋាភិបាលមជ្ឈឹមត្រួតត្រាទៅលើដីភ្នំដែលអាចប្រមូលផលបាននោះគឺបានកំនត់យ៉ាងចង្អៀតគោល- | • អាជ្ញាធរឃុំគឺមានការឆ្លើយតបយ៉ាងខ្ពស់ដល់តំរូវការជីវភាពរបស់សហគមន៍ អរគុណចំពោះទំនាក់ទំនងសង្គមដ៏រឹងមាំ។<br>• គណកម្មការគ្រប់គ្រងទីជំរាលទឹកភ្លៀងមិនបើកឳកាសដល់ការព្រួយបារម្ភរបស់អ្នកស្រុកដែលសកម្មភាពរបស់ខ្លួនបង្កើតអោយ |

| | | | | |
|---|---|---|---|---|
| | | | បំនងផ្នែកបរិស្ថាន។<br><br>**ភាពមានកំរិតនៃវិមជ្ឈការនយោបាយ** | មានភាពមិនច្បាស់លាស់ផ្នែកសិទ្ធិកាន់កាប់សំរាប់សហគមន៍ ហើយបានកាត់ផ្តាច់ជាធរមាននូវជំរើសនានាផ្នែកជីវភាព។ |
| **ខេត្តរតនៈគីរី កម្ពុជា** | • មានធនធានព្រៃឈើដ៏មានតំលៃ។<br>• មានការកើនឡើងនូវការប្រកួតប្រជែងគ្នាក្នុងចំណោមសហគមន៍មូលដ្ឋាន រដ្ឋាភិបាលនិងផ្នែកឯកជននានា។<br>• មានអត្រាចំរុះជនជាតិភាគតិចខ្ពស់។ | • ផែនការអភិវឌ្ឍន៍វិមជ្ឈការតាមរយៈកម្មវិធីម្ចាស់ជំនួយ(សិលា) | • សហគមន៍ជ្រើសរើសមេដឹកនាំឃុំ និងគណកម្មការអភិវឌ្ឍន៍ឃុំគ្រប់គ្រងនូវថវិការអភិវឌ្ឍន៍ទាំងឡាយ(ផ្តល់អោយដោយរដ្ឋាភិបាលជាតិពីមូលនិធិម្ចាស់ជំនួយនានា។<br>• មន្ត្រីថ្នាក់ខេត្តទាំងឡាយផ្តល់ការគាំទ្រផ្នែកច្បាប់ដល់គំនិតផ្តួចផ្តើមនិងផលប្រយោជន៍ទាំងឡាយរបស់អ្នកស្រុក។<br><br>**ភាពមានកំរិតនៃវិមជ្ឈការនយោបាយ** | • ដំណើរការផែនការវិមជ្ឈការបង្កើតអោយមានវេទិការសំរាប់សហគមន៍ដើម្បីប៉ាន់ប្រមាណនូវធនធានទាំងឡាយក្នុងមធ្យោបាយសមាហរណកម្មនិងបែបផែននៃសកម្មភាពអភិរក្ស។<br>• ប្រជាជនមូលដ្ឋានខ្វះនូវសិទ្ធិការពារធនធានពីផលប្រយោជន៍ផ្នែកពាណិជ្ជកម្មខាងក្រៅ ហេតុដូច្នេះវាបានបំផ្លាញនូវផលប្រយោជន៍បរិស្ថាននិងជីវ |

| | | | | |
|---|---|---|---|---|
| | | | | ភាពរស់នៅនៃការធ្វើវិមជ្ឈការ។ |
| **ខេត្តដាឡាក់ វៀតណាម** | • ដីព្រៃរិចរឹល<br>• អត្រាពាណិជ្ជកម្មផ្នែកកសិកម្មខ្ពស់។<br>• ចំនួលស្រុកនិងសម្ពាធប្រជាជនក្រុមជាតិពន្ធដែលនៅសល់ក្លាយជាអ្នកដែលមានអត្រាភាគរយតូចបំផុតនៅក្នុងក្រុមទាំងមូល។ | • ជាតំបន់សេដ្ឋកិច្ចថ្មីនិងមានគោលនយោបាយបំ-លាស់ទី។<br>• ច្បាប់ប្រើទឹកមានការទទួលស្គាល់ស្ថាប័នផ្សេងៗគ្នាក្នុងការគ្រប់គ្រងទឹកដោយស្របច្បាប់។ | • សមាគមប្រើប្រាស់ទឹកទាំងឡាយមានឱកាសក្នុងការរៀបចំនិងផ្តល់អោយកសិករនូវវេទិការមួយសំរាប់វាយតំលៃនិងសំរបសំរួលធារាសាស្ត្រ។<br>• គណកម្មការប្រជាជនគាំទ្រគំនិតផ្តួចផ្តើមរបស់ប្រជាជន បកស្រាយពន្យល់ច្បាប់ ជាពិសេសនៅក្នុងកំរិតថ្នាក់ខេត្ត។<br><br>**មានការកើតឡើងដូចជាការប្រគល់អំណាចអោយផ្នែកឯកជន ប៉ុន្តែមានកិច្ចសហការគ្រប់គ្រងយ៉ាងមានប្រសិទ្ធិភាពជាមួយអាជ្ញាធរមូលដ្ឋាន** | • មធ្យោបាយពហុភាគីបង្កើនសំលេងរបស់ប្រជាជននៅក្នុងការប្រើប្រាស់ទឹកនិងការទិញយកផ្តាច់មុខសំរាប់វិធានការអភិរក្ស។<br>• ក្រុមអ្នកប្រើប្រាស់ទាំងឡាយផ្តល់វេទិការដល់បញ្ហាការគ្រប់គ្រងទឹកក្នុងមធ្យោបាយសមាហរណកម្មប្រសើរជាងមុន ប៉ុន្តែមិនរួមបញ្ចូលនូវទឹកក្រោមដីនោះទេ។<br>• គំរូនៃក្រុមអ្នកប្រើប្រាស់ទាំងឡាយបានលើកឡើងបញ្ហាសមភាព: តើនរណាត្រូវផាត់ចេញ?<br>• គណកម្មការគ្រប់គ្រង |

| | | | | |
|---|---|---|---|---|
| | | | | ទីភ្នាក់ងារចំរុះបានជួយបង្កើនប្រសិទ្ធិភាពនៃការធ្វើអន្តរាគមន៍របស់រដ្ឋាភិបាល។ |
| **សង្កាត់បាវឆានខេត្តយុនណានប្រទេសចិន** | • ទីជំរាលទឹកភ្លៀងរិចរឹលដីព្រៃ។<br>• កសិកម្មផ្នែកពាណិជ្ជកម្មដែលចេះតែកើនឡើង។ | • គោលនយោបាយប្រជាធិបតេយ្យឧបនីយកម្មនៅតាមភូមិ។<br>• វិមជ្ឈការសារពើពន្ធ។ | • ប្រជាជនសហគមន៍ជ្រើសរើសមន្ត្រីភូមិទាំងឡាយពីបញ្ជីគណបក្ស ភូមិទាំងឡាយមានការកើនឡើងនូវអាណត្តិនានាក្នុងការគ្រប់គ្រងធនធានធម្មជាតិការកំណត់ដែលមានភាពស្រពិចស្រពិល។<br>• រដ្ឋាភិបាលនៅលំដាប់ថ្នាក់និមួយៗទទួលខុសត្រូវក្នុងការបង្កើនប្រាក់ចំណូលរបស់ខ្លួន។<br>**វិមជ្ឈការនយោបាយ** | • ខ្វះការសំរបសំរួលក្នុងចំណោមភូមិ ទីប្រជុំជននានានិងការទន់ខ្សោយនៃស្ថាប័នការពារបរិស្ថាននៅក្នុងតំបន់ទីជំរាលរងទឹកភ្លៀងធ្វើអោយវាមានការរិចរឹលកាន់តែខ្លាំងឡើង។<br>• ការជំរុញទឹកចិត្តដើម្បីទូទាត់ធនធានធម្មជាតិជាមួយប្រាក់ចំណូល។ |
| **ខេត្តលួងប្រាបាងឡាវ** | • ព្រៃរិចរឹល<br>• អត្រាចំរុះជនជាតិភាគតិចខ្ពស់។<br>• ភាពចំរុះផ្នែកខាងជីវភាពមានតិចតួច។ | • ផែនការប្រើប្រាស់ដីនិងចែកចាយកម្មសិទ្ធិដីតាមរយៈកម្មវិធីម្ចាស់ជំនួយ | • ភូមិទាំងឡាយមានការកើនឡើងនូវតួនាទីក្នុងការធ្វើផែនការប្រើប្រាស់ដីធ្លី<br>• គណកម្មការបែងចែកដីធ្លី (រួមមានអ្នកតំណាងភូមិ | • ដំណើរការប្រឹក្សានៅមូលដ្ឋាននាំអោយមានសកម្មភាពរួមទៅលើការបង្កើននូវការកំនត់ព្រំដែន ដំណោះ |

| | | | | |
|---|---|---|---|---|
| | | (កម្មវិធីព្រៃឈើស៊ុយអែដ-ឡាវ) | ដែលបានជាប់ឆ្នោត និងបណ្តាញភ្នាក់ងារទាំងឡាយ) ជាអ្នកគូសបន្ទាត់ព្រំដែនភូមិនិងប្លង់ដី។<br>• ការសហការគ្រប់គ្រងនៅក្នុងកិរិតនៃការអភិវឌ្ឍន៍<br>• មន្រ្តីខេត្តមានការកើនឡើងនូវតួនាទីនៅក្នុងផែនការអភិវឌ្ឍន៍តំបន់។<br>**វិមជ្ឈការរដ្ឋបាលជាមួយនិងការកើនឡើងនូវយន្តការប្រឹក្សា** | ស្រាយជំលោះនានា ការគ្រប់គ្រងភ្លើងឆេះព្រៃ។<br>• គោលការណ៍រដ្ឋាភិបាលមជ្ឈឹមដ៏រឹងត្អឹងរារាំងជំរើសដែលគាប់ប្រសើរនានាក្នុងបញ្ហាសុវត្ថិភាពស្បៀង។<br>• បណ្តាញទីភ្នាក់ងារនានាខ្វះអ្នកបច្ចេកទេស និងការគាំទ្រដើម្បីអនុវត្តន៍ភារៈកិច្ចរបស់ពួកគេ។ |
| **ខេត្តឈៀងម៉ៃ (តំបន់ទីជំរាលរងទឹកភ្លៀងម៉ែចេម) ថៃ** | • ពាណិជ្ជកម្មផ្នែកកសិកម្ម<br>• អត្រាចំរុះជនជាតិភាគតិចខ្ពស់។ | • ការកើនឡើងនូវការទទួលខុសត្រូវទៅលើអង្គការរដ្ឋបាលតំបន់នានា(អាជ្ញាធរអនុស្រុក) | • ភូមិទាំងឡាយមានការកើនឡើងនូវសំលេងក្នុងការធ្វើសេចក្តីសំរេចចិត្តអភិវឌ្ឍន៍តាមរយៈការបោះឆ្នោតគណកម្មការតំបន់។<br>• អង្គការតំបន់ទទួលកាន់កាប់រាល់ការទទួលខុសត្រូវទាំងឡាយសំរាប់កិច្ច | • បរិស្ថានគឺជាភាពពុំចាំបាច់នៅក្នុងការចំណាត់ថ្នាក់អត្តិភាពក្នុងការបោះឆ្នោត និងដំណើរការពិគ្រោះយោបល់នានា។<br>• ខ្វះការបែងចែកអោយបានច្បាស់លាស់នូវពលកម្មរវាងរដ្ឋាភិ |

| | | | | |
|---|---|---|---|---|
| | | | អភិវឌ្ឍន៏នានានៅក្នុងយុត្តាធិការ(ហេដ្ឋារចនាសម្ពន្ធ័ ការផ្តល់សេវាបំរើការគ្រប់គ្រងធនធានធម្មជាតិ)។<br>**វិមជ្ឈការនយោបាយ** | បាលក្នុងស្រុកនិងបណ្តាញទីភ្នាក់ងារនានាដែលបង្កើតអោយមានការភ្ជាំងភ្ជាត់ការតានតឹងនានានៅក្នុងការគ្រប់គ្រងធនធានធម្មជាតិ។<br>• អង្គការសហគមន៏នានានិងបណ្តាញការងារដែលមានស្រាប់ពង្រឹងដំណើរការវិមជ្ឈការ។ |

ជំពូកខាងក្រោយនៃឯកសារនេះគឺពិនិត្យមើលទៅលើបញ្ហាដ៏សំខាន់ពីរនៃទំនាក់ទំ-នងការទទួលខុសត្រូវទាំងឡាយដែលបានបង្កើតឡើងក្រោមការធ្វើវិមជ្ឈការនិងការអនុវត្តន៍នានារបស់ពួកគេថាតើត្រូវធ្វើដោយវិធីណាក្នុងការគ្រប់គ្រងធនធានធម្មជាតិនិងជីវភាពរស់នៅ--ការទទួលខុសត្រូវរបស់រដ្ឋាភិបាលមូលដ្ឋានចំពោះរដ្ឋាភិបាលមជ្ឈឹមនិងការទទួលខុសត្រូវរបស់រដ្ឋាភិបាលមូលដ្ឋានចំពោះប្រជាជនក្នុងមូលដ្ឋាន។ បន្ទាប់មកយើងពិនិត្យមើលទំនាក់ទំនងស្ថាប័នផ្សេងទៀតដែលផ្លាស់ប្តូរក្រោមកំណែទំរង់វិមជ្ឈការៈ ទំនាក់ទំនងនៃទីភ្នាក់ងាររដ្ឋាភិបាលផ្សេងៗនៅកំរិតថ្នាក់ស្រុកនិងឥទ្ធិពលរបស់ពួកគេទៅលើការគ្រប់គ្រងធនធានធម្មជាតិ។ យើងធ្វើការសន្និដ្ឋានវគ្គមួយទៅលើតួនាទីនៃការប្រមូលចងក្រងសហគមន៍ក្នុងការទាមទារអោយមានអធិការកិច្ចល្អ និងសេចក្តីសន្និដ្ឋានជាទូទៅខ្លះៗនិងការផ្តល់អនុសាសន៍ដែលលេចចេញពីការសិក្សាប្រៀបធៀបនេះ។

## ក្របខ័ណ្ឌគោលនយោបាយ

ចេតនាមួយដែលកាត់ផ្តាច់រាល់ការវិភាគផ្នែកនយោបាយនៅក្នុងការស្រាវជ្រាវនេះៈ គំនិតនៃទំរង់ខ្លះក្នុងការបង្កើនការចូលរួមជាសាធារណៈនៅក្នុងសេចក្តីសំរេចចិត្តផ្នែកបរិស្ថាននិងការអភិវឌ្ឍន៍មូលដ្ឋានវានឹងជំរុញអោយមានប្រសិទ្ធិភាពនៃគោលនយោបាយ។ រដ្ឋាភិបាលជឿជាក់ថាការដើរក្នុងទិសដៅនេះនឹងបង្កើនឱ-កាសនានានៃគោលបំណងកាត់បន្ថយភាពក្រីក្រនិងទទួលបាននូវការការពារបរិ-ស្ថាន។

ទោះជាយ៉ាងណាក៏ដោយយើងបានរកឃើញឧបសគ្គដ៏ចំបងបីនៅក្នុងក្របខ័ណ្ឌគោលនយោបាយដែលអាចបំផ្លាញសក្តានុពលនៃផលប្រយោជន៍ទាំងឡាយនៃការបង្កើនភាពជាតំណាងមូលដ្ឋានក្នុងការធ្វើសេចក្តីសំរេចចិត្តនិងដំណើរការគ្រប់គ្រងៈ (១)ការខ្វះខាតភាពច្បាស់លាស់ថាតើគួរអនុវត្តន៍កំណែទំរង់បែបណា? (២)ការខ្វះខាតភាពដែលអាចបត់បែនបានដើម្បីអនុញ្ញាតិអោយការអនុវត្តន៍ធនធានធម្មជាតិក្នុងមូលដ្ឋានតាមលំដាប់លំដោយមួយដែលមានប្រយោជន៍ផ្នែកខាងបរិស្ថាន និង(៣)ភាពគ្មានសុឆន្ទៈរបស់រដ្ឋាភិបាលមជ្ឈឹមដើម្បីផ្ទេរធនធានធម្ម-ជាតិដែលអាចទាញយកផលបានអោយទៅដល់ដៃប្រជាជនមូលដ្ឋាន។

*ការខ្វះខាតភាពច្បាស់លាស់ថាតើគួរអនុវត្តន៍កំណែទំរង់បែបណា?*

ទីមួយ វាមិនមែនជារឿងប្លែកគ្នានោះទេសំរាប់អ្នកដើរតួនាទីទាំងឡាយនៅថ្នាក់មូលដ្ឋានដែលតែងតែខ្វះពត៌មានអំពីភារកិច្ចជាមូលដ្ឋានរបស់ពួកគេបន្ទាប់ពីការធ្វើវិមជ្ឈការ។ ការយល់ច្រលំបែបនេះរាំងស្កាត់ការចូលរួមនិងដំណើរការពិគ្រោះយោបល់នៅថ្នាក់មូលដ្ឋាន ហើយជាហេតុធ្វើអោយពន្យឺតសមិទ្ធិផលនិងលទ្ធផលជាផ្លែផ្កាទាំងឡាយ។ នៅខេត្តលួងប្រាបាង ប្រទេសឡាវមន្ត្រីរុក្ខាប្រមាញ់ស្រុកនិងមេដឹកនាំភូមិទាំងអស់ទទួលបានអំណាចក្នុងការធ្វើប្លង់ដីនិងការបែងចែកដីព្រៃនិងដីកសិកម្មនានា។ ប៉ុន្តែពួកគេពុំមានគោលការណ៍អនុវត្តន៍ជាពីស្តារក្នុងការចង្អុលបង្ហាញដល់ពួកគេនោះទេ។ ភាគច្រើនបណ្តាភូមិទាំងឡាយនៅក្នុងករណីសិក្សាបានផលិតចេញនូវផែនទីសាធារណៈដែលបង្ហាញអំពីព្រំប្រ-ទល់ប្រើប្រាស់ដីធ្លីបន្ទាប់ពីទទួលបានការបែងចែកដីធ្លី។ តែទោះជាយ៉ាងណាគេពុំបានដាក់នូវបទដ្ឋានផ្សេងៗអ្វីដែរប្រហែលក៏ព្រោះមកពីមន្ត្រីទាំងនោះពុំបានច្បាស់លាស់នូវភាពដែលអាចធ្វើទៅបាននៅក្នុងប្រព័ន្ធថ្មីនេះនិងភាពមិនច្បាស់លាស់ក្នុងលទ្ធភាពអនុវត្តន៍បទដ្ឋាននានា។ នៅក្នុងខេត្តដាឡាក់ប្រទេសវៀតណាម ទីភ្នាក់ងារនិងក្រុមកសិករទាំងឡាយនៅក្នុងថ្នាក់មូលដ្ឋានកំពុងព្យាយាមអនុវត្តន៍នូវច្បាប់ប្រើប្រាស់ទឹកថ្មីជាមួយនិងការទទួលស្គាល់នូវតួនាទីអ្នកពាក់ព័ន្ធពហុភាគីក្នុងការគ្រប់គ្រងទឹក។ ទោះបីជាមានសមាគមអ្នកប្រើប្រាស់ទឹកនានាក៏ដោយក៏វាស្ថិតនៅក្រោមស្ថានភាពនិតិបញ្ញត្តិរបស់ប្រទេសវៀតណាមស្តីអំពីច្បាប់សហករណ៍។ ទោះជាយ៉ាងណាដោយសារខ្វះភាពពីស្តារនៃគោលការណ៍ដើម្បីដឹកនាំពួកគេនោះពួកគេក៏គ្មានសិទ្ធិច្បាស់លាស់ដើម្បីគ្រប់គ្រងផែនការធារាសាស្រ្តឬពួកគេគ្មានទំ-នាក់ទំនងការទទួលខុសត្រូវច្បាស់លាស់ជាមួយនិងទីភ្នាក់ងាររដ្ឋាភិបាលនានានោះដែរ។

នៅក្នុងខេត្តរតនៈគីរីប្រទេសកម្ពុជា ការធ្វើវិមជ្ឈការអាចពិពណ៌នាបានយ៉ាងប្រពៃថាជាដំណើរការមូលដ្ឋានឬពីក្រោមឡើងទៅលើដែលជាជោគជ័យនៅក្នុងបញ្ហាគោលនយោបាយនិងច្បាប់របស់រដ្ឋាភិបាលមជ្ឈឹម។ ច្បាប់ជាតិទាំងឡាយគ្រប់គ្រងកិច្ចការពារធនធានធម្មជាតិគឺមានភាពទន់ខ្សោយនិងការអនុវត្តន៍ធូរលុង។ នៅពេលដែលមានសកម្មភាពអភិវឌ្ឍន៍របស់ប្រជាជនមូលដ្ឋានក្រោមកម្ម-

វិធីសិលានោះវាបានលេចឡើងនូវជំលោះជាមួយក្រុមហ៊ុនកាប់ឈើឬគំរោងអភិវឌ្ឍន៏នានារបស់អ្នកមានឥទ្ធិពលដែលមកពីខាងក្រៅនោះគឺឃើញមានការខ្វះខាតភាពច្បាស់លាស់ផ្នែកខាងផ្លូវច្បាប់សំរាប់ដោះស្រាយជំលោះនានានោះ។ បញ្ហានេះបាន នាំអោយមានដំណោះស្រាយផ្តោតជាពិសេសជាមួយនិងភាពមិនខ្ចាប់ខ្ជួនសំរាប់ ប្រជាជននិងបញ្ហាជីវភាពរបស់ពួកគេឬនិយាយបានយ៉ាងសាមញ្ញថាជាការខ្វះខាតនូវសកម្មភាពរបស់រដ្ឋាភិបាល។

*ភាពគ្មានអំណាចគ្រប់គ្រាន់នៅថ្នាក់មូលដ្ឋាន*

ទីពីរ និងដោយភាពផ្ទុយគ្នា ការបង្ខិតបង្ខំរបស់រដ្ឋាភិបាលលើគោលការណ៏បរិស្ថានដ៏តឹងរឹងជ្រុលអាចផ្តល់ផលអវិជ្ជមានផងដែរ។ នៅក្នុងប្រទេសដែលបានធ្វើការសិក្សានេះ វាជាការដូចៗគ្នាមួយដែលរដ្ឋាភិបាលទាំងឡាយដាក់ចេញនូវលក្ខណៈបច្ចេកទេសដ៏ជាក់លាក់ច្រើនជ្រុលពេកក្នុងពេលដែលខ្លួនដំណើរការធ្វើវិមជ្ឈការតែវិស័យជាក់លាក់ណាមួយ(តួយ៉ាង វិស័យព្រៃឈើ) ជាមួយនិងលទ្ធផលដែលអាជ្ញាធរមូលដ្ឋានទាំងនោះពុំមានលទ្ធភាពដើម្បីគាំទ្រប្រព័ន្ធគ្រប់គ្រងនានានៅក្នុងមូលដ្ឋានហើយដែលអាចមានប្រយោជន៏ដល់ប្រព័នអេកូឡូស៊ីនិងជីវភាពរស់នៅរបស់ពួកគេ។ ម្យ៉ាងវិញទៀតវាមានសារៈសំខាន់ណាស់សំរាប់គោលនយោបាយវិមជ្ឈការទាំងឡាយដើម្បីរក្សាតុល្យភាពមួយរវាងការផ្តល់គោលការណ៏គ្រប់គ្រាន់ទៅលើតួនាទីនិងការទទួលខុសត្រូវថ្មី(ដូចមានខាងលើ)ហើយនិងការដែលមិនបានផ្តល់នូវបទបញ្ញត្តិពីស្តារដល់រដ្ឋាភិបាលថ្នាក់ក្រោមដែលពួកគេគ្មានជំរើសនិងភាពដែលអាចបត់បែនបាន។

នៅល្វងប្រាបាងក៏ដូចជានៅកន្លែងដ៏ទៃទៀតនៃប្រទេសឡាវ រដ្ឋាភិបាលទាមទារអោយមានប្រព័ន្ធដ៏តានតឹងឆ្លាស់គ្នា៣ប្លង់ដែលជាផ្នែកមួយនៃដំណើរការបែងចែកដីធ្លីតាមបែបវិមជ្ឈការ។ ភាពរឹងត្អឹងផ្នែកខាងប្រព័ន្ធប្រើប្រាស់ដីធ្លីដែលដាក់ចុះអោយអនុវត្តន៏ដោយរដ្ឋាភិបាលមជ្ឈឹមគឺមានន័យថាជាការកំរិតដល់ប្រព័ន្ធប្រើប្រាស់ដីសំរាប់កសិកម្មពនេចរ ហើយវាមិនបានផ្តល់នូវសេចក្តីត្រូវការផ្នែកខាងជីវភាពរបស់ប្រជាជនមូលដ្ឋានឬវាក៏មិនបានរួមចំណែកដល់និរន្តភាពបរិស្ថាននោះដែរ។ ដូច្នេះវាគឺជាប្រព័ន្ធមួយដែលគ្មាននិរន្តភាពនោះទេព្រោះវាមិនអនុញ្ញាតិ

អោយមានពេលវេលាគ្រប់គ្រាន់ដើម្បីអោយដីដុះដាលល្អឡើងវិញ (ឧ.ការផលិតឡើងវិញដោយខ្លួនឯង) មុនពេលត្រូវប្រមូលផល។ ជាលទ្ធផលគឺការធ្វើអោយដីខ្សត់ខ្សោយគុណភាពលឿន។ បទពិសោធន៍នេះបានស្នើអោយរដ្ឋាភិបាលគួរតែទទួលស្គាល់ប្រព័ន្ធប្រើប្រាស់ដីបែបចំរុះដែលអាចជាតឹកតាងអោយឃើញថាវាមានលក្ខណៈនិរន្តភាពបរិស្ថាន។ ជំរើសផ្សេងទៀតក៏អាចជាការជួយដល់ប្រជាជនមូលដ្ឋានដើម្បីអភិវឌ្ឍន៍នូវឱកាសនានាសំរាប់ការបង្កើនប្រាក់ចំណូលពីការងារក្រៅចំការផងដែរ។

នៅក្នុងខេត្តញៀ អានភាគខាងជើងប្រទេសវៀតណាម មន្ត្រីស្រុកទាំងឡាយមានការទទួលខុសត្រូវថ្មីមួយសំរាប់ការគ្រប់គ្រងនិងការបែងចែកដីព្រៃ។ ប៉ុន្តែប្រភេទនៃការគ្រប់គ្រងព្រៃឈើដែលអនុញ្ញាតិដោយគោលនយោបាយជាតិនោះមានការកំរិតដ៏តឹងជ្រុលហួសហេតុ។ កម្មវិធីបែងចែកដីព្រៃនោះអនុញ្ញាតិអោយមានការចែកចាយនៃធនធានទាំងឡាយត្រឹមតែក្រុមគ្រួសារបុគ្គលតែប៉ុណ្ណោះ។ គោលនយោបាយជាតិទាត់ចោលនូវប្រព័ន្ធព្រៃឈើសហគមន៍ដែលប្រជាជនមូលដ្ឋានពេញចិត្តសំរាប់ផលប្រយោជន៍ទាំងឡាយផ្នែកខាងបរិស្ថាននិងសង្គមរបស់ពួកគេៈ ព្រៃឈើដែលគ្រប់គ្រងដោយសហគមន៍តែងតែផ្តល់នូវប្រយោជន៍សុវត្ថិភាពសង្គមទៅដល់គ្រួសារទាំងឡាយក្នុងអំលុងពេលដែលផលិតផលកសិកម្មរបស់ពួកគេមានការធ្លាក់ចុះឬក្នុងពេលដែលមានបញ្ហាលំបាកខាងសេដ្ឋកិច្ច។ ប្រព័ន្ធគ្រប់គ្រងព្រៃឈើផ្អែកលើសហគមន៍ទាំងនោះបានកើតមានឡើងនៅតំបន់ញៀអានរាប់សតវត្សរ៍មកហើយ (Vien, Huong et al, 2001 )។ ទោះបីជាសហគមន៍ព្រៃឈើនានាបានបាត់រូបរាងតាំងពីទសវត្សរ៍១៩៦០ក៏ដោយក៏សហគមន៍ព្រៃឈើដែលនៅសេសសល់ភាគច្រើនតែងមានលក្ខណ្ឌ (កំណត់យ៉ាងច្បាស់លាស់នូវក្រុមអ្នកប្រើប្រាស់ទាំងឡាយ សេចក្តីសំរេចចិត្តតាមបែបមតិភាគច្រើន និងគោលការណ៍ទាំងឡាយក្នុងការធ្វើអាជីវកម្មដ៏ឆ្លាតវៃ) ដែលជំរុញអោយមាននិរន្តភាពបរិស្ថាននិងសង្គមដ៏យូរអង្វែង។ ទោះជាយ៉ាងណានៅក្នុងក្របខ័ណ្ឌគោលនយោបាយបច្ចុប្បន្នសំរាប់ការបែងចែកដីនោះសហគមន៍ព្រៃឈើពុំត្រូវបានគេទទួលស្គាល់ក្នុងផ្លូវច្បាប់នោះទេ។

កម្មវិធីសំរាប់ការស្តារព្រៃឈើ៥លានហិកតាជាទូទៅ(កម្មវិធីដ៏លេចធ្លោផ្សេងមួយទៀតនៅខេត្តញៀអាន) បានអំពាវនាវអោយមានការពិភាក្សាជាសាធារណៈធំទូលាយជាងកម្មវិធីមុនៗរបស់រដ្ឋាភិបាល។ ទោះបីជាយ៉ាងណាកម្មវិធីនេះបានបញ្ជាក់អំពីប្រភេទដើមឈើដ៏ជាក់លាក់សំរាប់ដាំ។ ប្រភេទឈើទាំងនេះជានិច្ចកាលគឺជាប្រភេទដើមឈើដែលនាំយកមកពីខាងក្រៅប្រទេស ដូចជាដើមប្រេងខ្យល់ដែលវាប្លែកនិងមិនមានផលប្រយោជន៏អ្វីទាល់តែសោះចំពោះអ្នកស្រុក។ករណីសិក្សាបានរកឃើញថាសេវ៉ាផ្សព្វផ្សាយដែលផ្តល់ជូននូវប្រភេទឈើដែលកំនត់ទុកជាមុននេះគឺថាជាស្វយ័ប្រវត្តិត្រូវបានប្រជាជនមូលដ្ឋានបដិសេធចោលព្រោះពួកគេគ្មានការពេញចិត្តពេញថ្លើមចំពោះរបស់ទាំងនេះទេ។ គ្រាប់ពូជទាំងឡាយត្រូវបានអសារឥតការព្រោះការបែងចែកអោយរបស់រដ្ឋាភិបាលមិនសមស្របជាមួយនិងតំរូវការប្រជាជនមូលដ្ឋាន។ កម្មវិធីនេះមិនត្រឹមតែបរាជ័យក្នុងការបង្កើនព្រៃឈើជុំកំភ្លូននៅញៀអាននោះទេ ប៉ុន្តែវាថែមទាំងបានកាត់បន្ថយនូវសុវត្ថិភាពស្បៀងប្រចាំគ្រួសាររបស់ប្រជាជនថែមទៀតព្រោះថាពួកគេបានចំណាយកំលាំងពលកម្មទៅក្នុងការដាំឈើដែលពុំបានផ្តល់ផលឬបង្កើនប្រាក់ចំនូលរបស់ពួកគេ។

ភស្តុតាងនេះបានបង្ហាញអោយឃើញថាសំរាប់សង្គមក្នុងការបង្កើនឡើងនូវប្រយោជន៏ទាំងឡាយនៃការធ្វើវិមជ្ឈការ(អ្នកតាក់តែងច្បាប់ត្រូវតែអនុញ្ញាតិអោយមានសេរីភាពក្នុងការធ្វើសេចក្តីសំរេចចិត្ត)តួយ៉ាងដូចជាការពេញចិត្តនូវប្រភេទដំណាំនានាជាដើមសំរាប់ថ្នាក់មូលដ្ឋាន។ កិរិតស្តង់ដារថ្នាក់ជាតិទាំងឡាយគឺមានភាពចាំបាច់ណាស់សំរាប់អភិរក្សទ្រព្យសម្បត្តិធម្មជាតិនិងសេវាកម្មនានាដែលបំរើផលប្រយោជន៏សាធារណៈនិងការការពារសុខភាពសាធារណៈ។ តួយ៉ាងនៅក្នុងវិស័យព្រៃឈើវាជាការសមរម្យណាស់ដែលរដ្ឋាភិបាលមជ្ឈឹមទាំងឡាយចូលរួមក្នុងការគូសប្លង់ដើម្បីបង្កើតឡើងនូវតំបន់ការពារនានាសំរាប់ជាសារៈសំខាន់ជាតិនិងអន្តរជាតិនិងសំរាប់រក្សាអត្រាភាគរយនៃព្រៃឈើគ្របដណ្តប់លើផ្ទៃដីជាតិផងដែរ។

*ភាពខ្វះការគ្រប់គ្រងទៅលើធនធានដែលអាចទាញយកផលបានរបស់អ្នកស្រុក*

ទីបី តួនាទីនៃដំណើរការវិមជ្ឈការទាំងឡាយនៅក្នុងការបង្កើនភាពជាតំណាងមូលដ្ឋាននោះគឺជាការបំផ្លាញធនធានទៅវិញទេនៅពេលដែលអ្នកស្រុកទទួលបានអំណាចនៃការធ្វើសេចក្តីសំរេចចិត្តស្តួចស្តើងពេកនោះ។ តួយ៉ាងនៅខេត្តធួ ធានហួ(ភូមិភាគកណ្តាលប្រទេសវៀតណាម)អាជ្ញាធរឃុំនានាមានការទទួលខុសត្រូវថ្មីក្នុងការធ្វើផែនការអភិវឌ្ឍន៍មូលដ្ឋាន។ ឥឡូវនេះអាជ្ញាធរឃុំគ្រប់គ្រងមូលនិធិរដ្ឋាភិបាលដែលបានផ្តល់អោយក្រោមផែនការជំនួយដ៏ធំមួយ--១៣៥កម្មវិធីសំរាប់គាំទ្រដល់សហគមន៍ក្រីក្របំផុតទាំងឡាយនៅក្នុងប្រទេសវៀតណាម។ អាជ្ញាធរឃុំទាំងនោះសប្បាយចិត្តនិងទំនាក់ទំនងដ៏ល្អជាមួយនិងការទទួលខុសត្រូវខ្ពស់ចំពោះសមាជិកសហគមន៍និងអរគុណចំពោះចំនងសង្គមដ៏រឹងមាំហើយនិងក្របខ័ណ្ឌរួមមួយសំរាប់ការបញ្ជាក់អំពីវប្បធម៌។ ទោះបីជាយ៉ាងនោះក៏ដោយអ្នកស្រុកទាំងនោះនិងការដឹកនាំរបស់ពួកគេគឺត្រូវបានគេដាក់កំរិតយ៉ាងធ្ងន់ធ្ងរនៅក្នុងលទ្ធភាពបំពេញនូវការឯកភាពរួមលើចំនុចអត្ថិភាពទាំងនោះក្នុងការអភិវឌ្ឍន៍ ព្រោះតំបន់សុវត្ថិភាពពីទឹកជំនន់នេះគឺជាដីខ្ពង់រាបនានានៅក្នុងព្រំប្រទល់ឃុំដែលនៅតែស្ថិតនៅក្រោមការត្រួតត្រាដែលមិនអាចជៀសវាងបានពីសំណាក់គណកម្មការគ្រប់គ្រងទីជំរាលរងទឹកភ្លៀងមជ្ឈឹម។

ប្រព័ន្ធនេះបង្កើតអោយមាននូវកង្វះខាតការលើកទឹកចិត្តសូម្បីតែការធ្វើវិនិយោគទុននៅក្នុងឃុំក្នុងរយៈពេលខ្លីក៏ដោយ ព្រោះដីអាចត្រូវគេរឹបអូសយកវិញតាមរយៈការបញ្ជូនកំនត់ហេតុខ្លីមួយដោយគណកម្មការនេះ។ ជួនកាលគណកម្ម-ការប្រកាសយកដីសំរាប់ការដាំដើមឈើដែលទោះជាដីនោះបានដាំដំណាំឈើហូបផ្លែរួចហើយក៏ដោយគឺគេបង្ខំអោយប្រជាជនបេះផ្លែទាំងមុនទុំ។ ប្រជាជននិងអ្នក-ដឹកនាំឃុំចង់ធ្វើការអភិវឌ្ឍន៍នូវដីចំណោតដែលឥតជីជាតិ(ដែលនៅខាងក្រៅនៃតំបន់រងទឹកភ្លៀង)ដោយគំរោងកសិរុក្ខាកម្មនិងការដាំឈើពូជនៅក្នុងស្រុកដើម្បីបង្កើនជីវភាពរបស់ពួកគេ ហើយក្នុងពេលជាមួយគ្នានេះពួកគេអាចបន្ថយបាននូវគ្រោះថ្នាក់ទាំងឡាយពីទឹកជំនន់ក៏ដូចជាស្ថេរភាពជើងភ្នំផងដែរ។ ការបាត់បង់នៃដីវាលស្រែនិងដីសួនច្បារដំណាំទាំងឡាយក្នុងអំលុងពេលនៃជំនន់ទន្លេថ្មីៗនេះគ្រាន់តែបានបង្កើតអោយមានលទ្ធភាពការល្បួងចិត្តច្រើនជាងមុននៅក្នុងក្រសែភ្នែក

របស់អ្នកស្រុកនិងអ្នកដឹកនាំរបស់ពួកគេ។ ផែនការអស់ទាំងនេះវាមិនអាចក្លាយជាការពិតទេលុះត្រាតែមានការទទួលខុសត្រូវនៅក្នុងកំរិតមួយសំរាប់ការអភិវឌ្ឍន៍ដីព្រៃដោយមានការប្រគល់អំណាចពីរដ្ឋាភិបាលថ្នាក់មជ្ឈឹម។

ប្រជាជននៅក្នុងខេត្តរតនៈគីរី ភូមិភាគឥសាន្តប្រទេសកម្ពុជាក៏បានជួបប្រទះនូវបញ្ហាស្រដៀងគ្នានោះដែរ។ ការផ្តួចផ្តើមឡើងនូវទំរង់ការចូលរួមក្នុងផែនការអភិវឌ្ឍន៍ទាំងឡាយនៃកម្មវិធីសិលាបានផ្តល់នូវផ្លែផ្កាគួរអោយកត់សំគាល់សំ-រាប់ជីវភាពរស់នៅរបស់ប្រជាជនមូលដ្ឋាននិងការគ្រប់គ្រងធនធានធម្មជាតិនានា។ ប៉ុន្តែផ្លែផ្កានេះត្រូវបានកំពុបចេញវិញដោយសារការបាត់បង់ជំនឿទៅលើហេតុផលអសន្តិសុខនៃកម្មសិទ្ធិរបស់ប្រជាជនមូលដ្ឋាន។ រដ្ឋាភិបាលជាតិបានប្រកាសថាព្រៃឈើជាសម្បត្តិរដ្ឋដោយពុំបានគិតគូរប្រព័ន្ធប្រើប្រាស់របស់ប្រជាជនអន្តោគ្រាមរាប់សតវត្សរ៍មកហើយនោះទេ (រដ្ឋាភិបាលទទួលស្គាល់ដីដែលទុកចោលទំនេរថាជាដីដែលគេបោះបង់ចោល) ហើយពួកគេលក់ព្រៃឈើនិងដីដែលទំនេរនោះជាសម្បទានដល់ក្រុមហ៊ុនឯកជននានាទៅវិញ។ ប្រសិនបើការធ្វើវិមជ្ឈការគឺជាការបង្កើតទំរង់យុទ្ធសាស្ត្រមួយសំរាប់ការកាត់បន្ថយភាពក្រីក្រនៅជនបទដូចដែលរដ្ឋាភិបាលនានាបានប្រកាសមែននោះ សហគមន៍ទាំងនោះត្រូវតែទទួលបាននូវសិទ្ធិធំទូលាយជាងនេះក្នុងការប្រើប្រាស់ធនធានដែលអាចទាញយកផលប្រយោជន៍បានសំរាប់ការចិញ្ចឹមជីវិតជាមូលដ្ឋានរបស់ពួកគេ។

## ភាពជាតំណាងនិងការចូលរួម

ផលប្រយោជន៍នានារបស់ប្រជាជនមូលដ្ឋានគឺបានបង្ហាញតាមរយៈដំណើរការធ្វើវិមជ្ឈការគឺតាមរយៈយន្តការពីរដ៏សំខាន់ៈ ការបោះឆ្នោតនិងការពិគ្រោះ-យោបល់នានានៅថ្នាក់មូលដ្ឋាន។ តាមទ្រឹស្តី យន្តការទាំងពីរនេះគឺអាចជំរុញការទទួលខុសត្រូវនៅក្នុងការធ្វើអភិបាលកិច្ចបរិស្ថាន។ តែបើតាមការអនុវត្តន៍វិញប្រសិទ្ធិភាពរបស់ពួកគេក្នុងការធ្វើអោយអាជ្ញាធរទាំងនោះឆ្លើយតបចំពោះការព្រួយបារម្ភរបស់សមាជិកខ្លួននោះគឺវាស្ថិតនៅលើការអនុវត្តន៍របស់ពួកគេទាំងស្រុង។

*ការបោះឆ្នោត*

បទពិសោធន៍ជាមួយនិងការបោះឆ្នោតនៅមូលដ្ឋានទាំងឡាយគឺមានការខុសប្លែកគ្នាពីករណីមួយទៅករណីមួយដែលកំពុងឆ្លុះបញ្ចាំងអោយឃើញពីភាពខុសគ្នាដ៏ធំនៅក្នុងប្រព័ន្ធនយោបាយក្នុងចំណោមបណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍។ ភាពខុសគ្នាទាំងនេះគឺចាត់លំដាប់ថ្នាក់ពីប្រជាធិបតេយ្យពហុបក្សនៅប្រទេសថៃទៅដល់ប្រទេសដែលមានគណបក្សទោលដូចជាវៀតណាម ឡាវនិងចិន។ ការខុសប្លែកគ្នានៅក្នុងប្រព័ន្ធនយោបាយទាំងនេះបានការអនុវត្តន៍យ៉ាងជ្រាលជ្រៅដើម្បីប្រសិទ្ធិភាពនៃការបោះឆ្នោតទាំងឡាយដែលជាយន្តការនៃការទទួលខុសត្រូវ។

ទីមួយ យើងបានពិនិត្យមើលទៅលើតួនាទីនៃការបោះឆ្នោតគឺជាការចងភ្ជាប់រដ្ឋាភិបាលមូលដ្ឋានអោយទទួលខុសត្រូវចំពោះការអនុវត្តន៍បរិស្ថានដ៏ទន់ជ្រាយ។ យើងបានរកឃើញឧទាហរណ៏មួយនៅពេលដែលការបោះឆ្នោតទាំងនោះបានបង្ហាញជាតឹកតាងនៅក្នុងបញ្ហានេះដូចជាការបោះឆ្នោតសំរាប់ក្រុមអ្នកគ្រប់គ្រងភូមិនៅខេត្តភូ ថូ ប្រទេសវៀតណាមបានជួយជីករឹសគល់អំពើពុករលួយដែលពាក់ពន្ធ័ជាមួយនិងធនធានធម្មជាតិ។ ប្រជាជនបានបើកមុខមន្ត្រីក្នុងស្រុកដែលបានប្រើប្រាស់តួនាទីថ្មីរបស់គាត់ទាក់ទងជាមួយនិងការកាប់ឈើហ៊ុបខុស-ច្បាប់សំរាប់ហោប៉ៅផ្ទាល់ខ្លួន។ ប្រជាជនបានបោះឆ្នោតទំលាក់គាត់ចេញពីមុខតំណែងក្នុងឱកាសបោះឆ្នោតលើកក្រោយ។ នេះគឺគ្រាន់តែជាឧទាហរណ៏មួយអំពីប្រយោជន៏នៃការបោះឆ្នោតទាំងឡាយនៅក្នុងការជំរុញការទទួលខុសត្រូវផ្នែកបរិស្ថាន ការសិក្សាបន្ថែមទៀតគឺជាការចាំបាច់បំផុតទូទាំងករណីសិក្សាដើម្បីសំរេចចិត្តថាតើនៅក្រោមលក្ខណ្ឌ័អ្វីខ្លះដែលការបោះឆ្នោតគឺជាយន្តការមួយដែលមានការទទួលខុសត្រូវសំរាប់ការគ្រប់គ្រងបរិស្ថាន។

ទីពីរ យើងបានពិនិត្យមើលទៅលើប្រសិទ្ធិភាពនៃការបោះឆ្នោតទាំងឡាយក្នុងការបង្កើនកិច្ចការពារបរិស្ថានដោយរដ្ឋាភិបាលមូលដ្ឋាន ហើយយើងបានរកឃើញនូវលទ្ធផលលាយឡំគ្នា។ នៅក្នុងស្រុកម៉េចេមនៃខេត្តឈៀងម៉ៃ ភាគខាងជើងរបស់ថៃ អ្នកបោះឆ្នោតទាំងឡាយមាននិន្នាការចង់គាំទ្របេក្ខជនណាដែលអំពាវនាវអោយមានឱកាសក្នុងការអភិវឌ្ឍន៏សេដ្ឋកិច្ចនិងជីវភាពរស់នៅជាជាងកិច្ចការពារបរិស្ថាន[១១]។ នៅក្នុងខេត្តណានដែលនៅក្បែរខាង បញ្ហាបរិស្ថានបាន

ត្រូវគេចំណាត់ថ្នាក់យ៉ាងខ្ពស់។ បណ្តាញគ្រប់គ្រងព្រៃឈើភូមិបានបង្កើតកម្មវិធីការយល់ដឹងអំពីបញ្ហាព្រៃឈើនៅក្នុងបរិបទនៃការធ្វើយុទ្ធនាការបោះឆ្នោត។

គោលជំហរមួយនៃជំលោះរវាងអ្នកភូមិនិងអាជ្ញាធរទាំងឡាយទៅលើព្រំប្រទល់ឧទ្យានជាតិមួយបានបង្កើតឡើងនូវបេក្ខជននានាដែលមាននិន្នាការឆ្ពោះទៅរក "ពណ៌បៃតង"[១២]។ ទិន្នន័យដែលបង្កើតឡើងដើម្បីការបង្កើតតួនាទីនៃការបោះឆ្នោតមូលដ្ឋានជាពិសេសនៅក្នុងបញ្ហាការទទួលខុសត្រូវផ្នែកបរិស្ថានគឺនៅមានកំរិតតិចតួចនៅឡើយហើយវាជាប្រធានបទមួយដែលត្រូវសិក្សាបន្ថែមទៀត។ ទោះបីជាយ៉ាងណាការដែលប្រទេសថៃមានបទពិសោធន៍ដ៏តិចតួចនេះក៏ដោយក៏វាបានលើកឡើងនូវបញ្ហាដ៏មានសារៈសំខាន់នេះផងដែរ ដូចជាទិសដៅបរិស្ថាននិងការចិញ្ចឹមជីវិតអាចត្រូវរួមគ្នាឬញែកឃ្លាតពីគ្នានៅក្នុងកំរិតសហគមន៍។ វាមិនមានភាពចាំបាច់នៃតំរូវការមូលដ្ឋានសំរាប់កិច្ចការពារបរិស្ថាននោះទេប៉ុន្តែការទាមទារទាំងឡាយគឺវាស្ថិតនៅលើអ្នកបោះឆ្នោតដែលយល់ដឹងអំពីផលប្រយោជន៍របស់វា។ ជាលទ្ធផលការបង្កើតដោយប្រុងប្រយ័ត្ននូវរូបមន្តទាំងឡាយដែលចាំបាច់ត្រូវជួយដល់អាជ្ញាធរមូលដ្ឋាននៅក្នុងការថ្លឹងថ្លែងការទទួលខុសត្រូវដល់ស្តង់ដារបរិស្ថានជាតិនិងតំបន់ជាមួយនិងតំរូវការនានាផ្នែកជីវភាពរបស់បណ្តាសមាជិកមូលដ្ឋាន។

*ដំណើរការពិគ្រោះយោបល់*

ការពិគ្រោះយោបល់ដោយរដ្ឋាភិបាលមូលដ្ឋានជាមួយនិងសមាជិករបស់ពួកគេគឺអាចដើរតួនាទីជាផ្នែកមួយនៃការធ្វើវិមជ្ឈការនយោបាយដូចយ៉ាងប្រទេសថៃដែលបានបង្កើតឡើងនូវរដ្ឋាភិបាលមូលដ្ឋាននានាដែលជាប់ឆ្នោតដោយប្រជាធិបតេយ្យ។ ការពិគ្រោះយោបល់នានាក៏មានតួនាទីមួយផងដែរនៅក្នុងការធ្វើវិមជ្ឈការរដ្ឋបាល ដូចយ៉ាងប្រទេសវៀតណាមនិងឡាវនៅពេលដែលខ្សែរយៈទីភ្នាក់ងារនៃរដ្ឋាភិបាលមជ្ឈឹមទទួលបាននូវការទទួលខុសត្រូវថ្មីនោះគឺបានស្នើអោយមានការទទួលយកនូវយោបល់និងការសហការនានាពីប្រជាជនមូលដ្ឋាន។

ករណីសិក្សាទាំងឡាយបានរកឃើញថាដំណើរការពិគ្រោះយោបល់នានាបានបង្កើតអោយមានបរិស្ថាននៃការធ្វើសេចក្តីសំរេចចិត្តថ្នាក់មូលដ្ឋានមួយដែលផ្តល់

នូវការបន្សាំការអនុវត្តន៏ការគ្រប់គ្រងធនធានធម្មជាតិកាន់តែមាននិរន្តភាព។ ការបង្កើតនូវវេទិការនានាបានលើកទឹកចិត្តប្រជាជនមូលដ្ឋានអោយទទួលយកនូវដើមទុននៃធនធានធម្មជាតិនៅក្នុងតំបន់របស់ពួកគេហើយនិងការពិចារណាអំពីប្រព័ន្ធផលិតភាពនិងជំរើសផ្នែកជីវភាពនៅជាមួយគ្នាតែម្តង។ នេះគឺជាករណីថាតើវាជាដំណើរការពិគ្រោះយោបល់ដែលផ្លូវផ្តងជាមួយនិងវិមជ្ឈការនយោបាយឬវិមជ្ឈការរដ្ឋបាល។

ឧទាហរណ៍ ការដកពិសោធន៏ការធ្វើផែនការវិមជ្ឈការនៃកម្មវិធីសិលានៅក្នុងប្រទេសកម្ពុជាគឺពុំបានគូសវាសផែនការដោយឡែកមួយដើម្បីផ្តោតលើបញ្ហាការគ្រប់គ្រងធនធានធម្មជាតិនៅតំបន់ខ្ពង់រាបនោះទេ។ ប៉ុន្តែវាបានកើតមានឡើងជាអត្ថិភាពខ្ពស់ក្នុងអំលុងពេលនៃការពិគ្រោះយោបល់ជាមួយប្រជាជនមូលដ្ឋាន។ ការពិគ្រោះយោបល់ទាំងឡាយបានជួយប្រមូលអាជ្ញាធរនិងសហគមន៏មូលដ្ឋានអោយធ្វើសកម្មភាពរួមគ្នាសំរាប់កិច្ចការពារបរិស្ថាន។ ពីព្រោះតែការទាមទាររបស់សហគមន៏ គណកម្មការអភិវឌ្ឍន៏ឃុំនានាបានសំរបសំរួលនូវការសាកល្បងធ្វើផែនការប្រើប្រាស់ដីធ្លីដោយមានការចូលរួម ដែលជានិច្ចកាលធ្វើជាមួយនិងកិច្ចគាំទ្របច្ចេកទេសមកពីខាងក្រៅ។ នៅក្នុងស្រុកមួយ អាជ្ញាធរឃុំនានាបានជួយសហគមន៏ក្នុងការបង្កើតគំរោងព្រៃឈើសហគមន៏សាកល្បងមួយ។

នៅក្នុងប្រទេសឡាវ អ្នកស្រុកទាំងឡាយបានប្រមូលផ្តុំគ្នាដើម្បីជួយមេដឹកនាំភូមិនិងមន្ត្រីរុក្ខាប្រមាញ់ស្រុកទាំងឡាយនៅក្នុងដំណើរការធ្វើបំនែងចែកដីធ្លី។ ក្រុមមន្ត្រីបែងចែកដីបានធ្វើការយ៉ាងជិតស្និទជាមួយនិង“ក្រុមផ្នែកជីវភាពរស់នៅ” នៅក្នុងភូមិដែលរួមមានប្រជាជនដែលធ្វើចំការពនេរចរ ធ្វើស្រែ អ្នកចិញ្ចឹមសត្វពាហនៈ អ្នកប្រមូលអនុផលព្រៃឈើនិងអ្នកធ្វើសកម្មភាព ផ្សេងៗទៀត។ ក្រុមផ្នែកជីវភាពបានផ្តល់អោយក្រុមរដ្ឋាភិបាលជាមួយនិងពត៏មានស្តីអំពីបែបផែនការប្រើប្រាស់ដីនានា ប្រវត្តិប្រព័ន្ធអេកូឡូស៊ីនិងសុវត្ថិភាពស្បៀងនៅក្នុងន័យនៃការអភិវឌ្ឍន៏រូបភាពនៃការដាក់បញ្ចូលគ្នាមួយក្នុងជំរើសនានាផ្នែកខាងជីវភាព។ នៅក្នុងការធ្វើយ៉ាងដូច្នេះ អ្នកស្រុកបានបង្កើនការយល់ដឹងផ្ទាល់របស់ពួកគេលើការធ្វើអត្ថិភាពសមាហរណកម្មកិច្ចអភិវឌ្ឍន៏ជាមួយនិងកិច្ចការអភិរក្ស[១៣]។

ទោះបីជាដំណើរការពិគ្រោះយោបល់ទាំងនោះបានបង្ហាញអំពីភាពដឹកនាំទៅ
រកសន្តនិយមផ្នែកបរិស្ថានក្នុងការធ្វើសេចក្តីសំរេចចិត្តឬការអនុវត្តន៏គោលនយោ
បាយជាទូទៅច្រើនក៏ដោយក៏ការសិក្សាបានបង្ហាញអោយឃើញពីចន្លោះប្រហោង
ជាច្រើនសំរាប់កែលំអរ។ លំដាប់ថ្នាក់នៃការកសាងសមត្ថភាពនិងវិធានការណ៍
ដែលអាចបត់បែនបាននានាគួរពង្រឹងដំណើរការនៃការពិគ្រោះយោបល់ដើម្បី
អោយពួកគេមានការឆ្លើយតបទៅនិងការព្រួយបារម្ភរបស់ប្រជាជនមូលដ្ឋាន។

អាជ្ញាធរមូលដ្ឋានទាំងឡាយតែងតែខ្វះខាតនូវជំនាញដែលទាមទារអោយ
មានដើម្បីសំរបសំរួលកិច្ចពិគ្រោះយោបល់សហគមន៏។ ការខ្វះខាតនូវវគ្គបណ្តុះ
បណ្តាលបុគ្គលិកទីភ្នាក់ងារនៅក្នុងវិធីនៃការចូលរួមត្រូវបានរកឃើញថាជាបញ្ហាដ៏
ជាក់លាក់មួយនៅទូទាំងករណីសិក្សាទាំងអស់។ ការអន់ខ្សោយខាងសមត្ថភាពនេះ
គឺជាបញ្ហាដ៏ពិសេសមួយនៅក្នុងទីកន្លែងសិក្សាដែលវាមិនមែនជាការផ្តោតនៃកម្មវិ-
ធី របស់ម្ចាស់មូលនិធិឬដែលវាពាក់ព័ន្ធជាមួយការធ្វើវិមជ្ឈការរដ្ឋបាលឬតាមបែប
ផែនសហគ្រប់គ្រងនោះទេ។ នៅក្នុងខេត្តដាឡាក់និងញៀ អាន នៃប្រទេសវៀត-
ណាមមន្ត្រីធារាសាស្ត្រនិងមន្ត្រីរុក្ខាប្រមាញ់បានលាតសន្ធឹងនូវកាតព្វកិច្ចពហុគុណ
របស់ពួកគេ។ ការពិគ្រោះយោបល់ជាមួយសហគមន៏ត្រូវបរាជ័យព្រោះបុគ្គលិក
គ្មានពេលវេលាឬធនធានផ្ទាល់ខ្លួនដើម្បីពិចារណាតើអ្វីដែលគួរប្រកាន់យក។

ការបង្ហូរពត៏មានដ៏ខ្សត់ខ្សោយរវាងអាជ្ញាធរមូលដ្ឋាននិងសហគមន៏នានា
បានបង្កើតអោយមាននូវការលំបាកមួយក្នុងការផ្តួចផ្តើមអោយមានកិច្ចពិគ្រោះ
យោបល់ដែលល្អ។ ជាការពិត ទិដ្ឋភាពមួយក្នុងចំណោមទិដ្ឋភាពដ៏មានសារៈ
សំខាន់ទាំងនោះរបស់រដ្ឋាភិបាលដែលគាំទ្រការធ្វើវិមជ្ឈការនោះគឺថាការបង្ហូរ
ពត៏មានពីលើចុះក្រោមដើម្បីបញ្ជូនដំនឹងដល់អ្នកដើរតួនាទីនានានៃសិទ្ធិនិងការ
ទទួលខុសត្រូវនិងការតំរូវនានាដើម្បីអោយមានការចូលរួមយ៉ាងមានអត្ថន័យជាទីបំ
ផុត។ នៅក្នុងសង្កាត់បាវ ឆាន ប្រទេសចិនគណកម្មការភូមិទាំងឡាយមានការ
ខ្សត់ខ្សោយក្នុងការបើកចំហរពត៏មានទៅដល់សហគមន៏ដែលទទួលរងផលប៉ះ-
ពាល់ទាំងនោះ។ អ្នកភូមិបានពេញចិត្តចំពោះការធ្វើតួនាទីរបស់គណកម្មការភូមិ
នៅពេលដែលពួកគេបានបិទប្រកាសដំណឹងអំពីសេចក្តីសំរេចនានាក្នុងបញ្ហាថវិការ
និងការអភិវឌ្ឍន៏ជាសាធារណះ។ ទោះជាយ៉ាងណាក៏ដោយការអនុវត្តន៏នេះគឺមិន

មែនជាក្រិត្យក្រមមួយទេ[១៤]។ ដូចគ្នានេះដែរនៅខេត្តធូធានហ្វ ប្រទេសវៀតណាម មន្ត្រីរដ្ឋាភិបាលមូលដ្ឋានមានការខ្វះខាតការទំនាក់ទំនងទៅអ្នកស្រុកអំពីគោល-នយោបាយជាមួយនិងការទទួលខុសត្រូវទាំងឡាយរបស់ខ្លួន។ ពត៌មានគោលនយោបាយនានាបានទៅដល់សហគមន៏តាមរយៈសារពត៏មាននិងទស្សនាវដ្ដីដែលនៅទីនោះការផ្សព្វផ្សាយពត៏មានទាំងឡាយត្រូវបានរាំងស្ទះដោយសារតែភាពអនក្ខរជនរបស់ប្រជាជនមូលដ្ឋាន។

ចុងបញ្ចប់ដំណើរការនៃកិច្ចពិគ្រោះយោបល់ទាំងឡាយប្រហែលជាត្រូវបានទន់ខ្សោយដោយសារតែការរើសអើងជាមួយនិងប្រជាជនដែលគេកំណត់ទុក"តែងតែផ្ដោតលើមូលដ្ឋានជនជាតិភាគតិច"។ តួយ៉ាង នៅពេលដែលគោលការណ៍ណែនាំទាំងឡាយសំរាប់ផែនការវិមជ្ឈការនិងថវិការត្រូវបានគេបញ្ជូនធ្លាក់មកដល់ភូមិនៃខេត្តភូ ថូប្រទេសវៀតណាមនោះក្រុមអ្នកគ្រប់គ្រងឃុំនិងស្រុកដែលមានការពាក់ព័ន្ធបានជ្រួតជ្រាបពត៏មានជាមួយការពិចារណាសំរាប់ការប្រើប្រាស់របស់អ្នកស្រុក។ បុគ្គលិកនៅក្នុងក្រុមអ្នកគ្រប់គ្រងទាំងឡាយមាននិន្នាការទៅរកក្រុមជនជាតិភាគច្រើន(គិញ)នៅពេលដែលអ្នកចូលរួមភាគច្រើននៅមូលដ្ឋាននោះគឺជាក្រុមជនជាតិភាគតិច។ ក្រុមពីអតីតកាលបានមន្ទឹលសង្ស័យអំពីលទ្ធភាពរបស់ប្រជាជនជនជាតិភាគតិចក្នុងការធ្វើសេចក្ដីសំរេចចិត្តលើការអភិវឌ្ឍន៏នានាសំរាប់ខ្លួនគេផ្ទាល់។ នៅក្នុងកិច្ចប្រជុំចំហរជាមួយនិងអ្នកស្រុក ផែនការទាំងឡាយត្រូវបាន"ពុំចាំបាច់បង្ហាញជាបញ្ជីសំរាប់ការពិភាក្សានោះទេ ប៉ុន្តែជាផែនការកំណត់ទុកមួយសំរាប់អោយគេបញ្ចេញទស្សនៈរបស់ពួកគេ" (Jorgensen et al., 2001, 25 )។ ជាលទ្ធផល ផែនការអភិវឌ្ឍន៏ភូមិទាំងឡាយបានបង្កើតឡើងមកដូចគ្នាបេះបិទទៅនិងឧទាហរណ៏នៃការចំណាយថវិការនានាដែលផ្ដល់ដោយអាជ្ញាធរថ្នាក់ខ្ពស់។ នៅក្នុងការអង្កេតលើភូមិនានាភាគច្រើនប្រជាជនបានមានអារម្មណ៏ថា ថវិការអភិវឌ្ឍន៏ភូមិនោះគឺពុំបានបំពេញនូវលទ្ធភាពបង្កើនជីវភាពរបស់អ្នកស្រុកបាននោះទេ។

**ប្រអប់ទីពីរៈ  តួនាទីរបស់ស្ត្រីនៅក្នុងផែនការវិមជ្ឈការ**

ការលំបាកដែលនៅតែមានគឺការដាក់បញ្ចូលដំណើរការមូលដ្ឋានទៅក្នុងទីតាំងនៃករណីសិក្សានោះគឺការចូលរួមដ៏តិចតួចរបស់ស្ត្រី។ ហេតុផលដែលស្ត្រីចូលរួមដ៏តិចតួចស្តួចស្តើងនេះគឺកើតមានឡើងដូចៗគ្នានៅគ្រប់ទីកន្លែងនៃករណីសិក្សាៈ ស្ត្រីជាពិសេសស្ត្រីជនជាតិភាគតិចគឺមានការអប់រំជាផ្លូវការតិចតួចជាងបុរស ដូច្នេះវាបានបំផ្លាញការជឿជាក់របស់ពួកគេ។ តួយ៉ាង ពួកគេហាក់ដូចជាមានការនិយាយភាសាជាតិតិចតួចក្នុងការទាមទារអោយផ្សាភ្ជាប់ជាមួយការិយាធិបតេយ្យរបស់រដ្ឋាភិបាល ហើយពួកគេហាក់ដូចជាមានការចេះដឹងតិចតួច។ សញ្ញាណប្រពៃណីរបស់ស្ត្រីគឺជាកសិករនិងជាអ្នកថែរទាំគ្រួសារ(មិនមែនជាអ្នកដឹកនាំ)នោះបានរួមចំនែកដល់ការខ្មាស់អៀនឬការមិនពេញចិត្តរបស់ស្ត្រីទាំងឡាយ ដូចនេះអ្នកដឹកនាំជាបុរសត្រូវសំនូមពរអោយស្ត្រីបង្កើតជាក្រុមៗនៅក្នុងចំណោមពួកគេ។ ទូនាទីថែរទាំគ្រួសាររបស់ពួកគេអាចធ្វើអោយពួកគេគ្មានពេលវេលាដើម្បីចូលរួមកិច្ចប្រជុំនានានៅក្នុងភូមិនោះទេ។

ការទាត់ចោលនូវសំលេងរបស់ស្ត្រីទាំងឡាយពីការធ្វើសេចក្តីសំរេចចិត្តនិងការអនុវត្តន៏គោលនយោបាយជាផ្លូវការចេញពីដំណើរការពិគ្រោះយោបល់គឺជាការដកហូតយកចេញផងដែរនូវទស្សនៈនិងបទពិសោធន៍ដ៏សំបូរបែបស្តីពីការគ្រប់គ្រងធនធានធម្មជាតិ។ ស្ត្រីទាំងឡាយបានសំដែងតួនាទីយ៉ាងធំទូលាយនៅក្នុងវិស័យកសិកម្ម ការប្រមូលផលព្រៃឈើ ការដងទឹកនិងការប្រើប្រាស់នៅក្នុងផ្ទះសំបែង។ វាមានការរំពឹងទុកថាការចូលរួមរបស់ស្ត្រីនៅក្នុងដំណើរការពិគ្រោះយោបល់អាចបង្កើនភាពសមស្របនិងប្រសិទ្ធិភាពនៃសេចក្តីសំរេចចិត្តនានាពាក់ព័ន្ធទៅនិងធនធានធម្មជាតិ។

ក្នុងចំណោមករណីសិក្សារបស់យើង ការចូលរួមដ៏មានអត្ថន័យរបស់ស្ត្រីគឺបានកើនឡើងនៅពេលណាដែលដំណើរការវិមជ្ឈការបានរួមបញ្ចូលគ្នានូវការតូសបួង់ដ៏ជាក់លាក់ជាមួយនិងការបរិយាយនៃគោលបំនងនេះតែប៉ុណ្ណោះ។ ការបំរុងទុកនូវចំនួនកៅអីក្រុមប្រឹក្សាភិបាលដ៏ជាក់លាក់ពេកសំរាប់ស្ត្រីនោះគឺពុំគ្រប់គ្រាន់ទេសំរាប់ការរួមចំនែកដែលចេះតែកើនឡើងរបស់ពួកគេ ដូចក្នុងករណីនៅភូមិភាគខាងជើងនិងភាគកណ្តាលនៃប្រទេសវៀតណាមបានបញ្ជាក់ស្រាប់។

វាជាការម្យ៉ាងដែរដែលមានការតំរូវអោយមានលំដាប់ថ្នាក់មួយនៃការធ្វើអន្តរាគមន៍នានាដើម្បីបង្កើតអោយមានការផ្លាស់ប្តូរ ត្ចយ៉ាងដូចជានៅក្នុងខេត្តរតនៈគីរីនៃប្រទេសកម្ពុជា។ នៅទីនោះកម្មវិធីសិលាបានគាំទ្រសកម្មភាពនានាដើម្បីលើកទឹកចិត្តអោយមានការជឿជាក់របស់ស្ត្រី--ដូចជាការអប់រំក្រៅប្រព័ន្ធ--និងការបង្កើតចំនួនកៅអីនៃគណកម្មការនានាសំរាប់ស្ត្រី។

## ការកាត់សេចក្តីនិងការត្រួតពិនិត្យ

តំបន់ខ្ពង់រាបគឺជាទីកន្លែងមួយដែលមានការកើនឡើងនូវការប្រកួតប្រជែងនិងជំលោះទៅលើសិទ្ធិនៃការប្រើប្រាស់និងការត្រួតត្រាធនធានធម្មជាតិ។ ករណីសិក្សាបានគូសបញ្ជាក់អំពីប្រភេទនៃជំលោះលើធនធានដែលមាននូវការរៀបចំនិងដំ-ណោះស្រាយ។ ជំលោះនានាដែលកើតឡើងរវាងសហគមន៍ ត្ចយ៉ាងនៅពេលដែលព្រំប្រទល់ភូមិដែលគេគូសបន្ទាត់ពីមុនមកឬនៅពេលដែលមានការផ្លាស់ប្តូររបបទឹកដែលប៉ះពាល់ការទំនាក់ទំនងអ្នកនៅខាងលើឬខាងក្រោមនៃខ្សែទឹក។ប្រជាជននិងទីភ្នាក់ងាររដ្ឋាភិបាលទាំងឡាយអាចមានជំលោះទៅលើស្ថានភាពអភិរក្សនៃតំបន់ការពារនានា ឬប្រជាជនមូលដ្ឋានទាំងឡាយអាចព្រហើនជាមួយនិងក្រុម-ហ៊ុនឯកជនទាំងឡាយដោយសារតែការផ្តល់អោយនិងការធ្វើអាជីវកម្មព្រៃឈើសម្បទាននានា។ ជំលោះអស់ទាំងនេះជាញឹកញាប់តែងតែពាក់ព័ន្ធជាមួយស្ថាប័ននៅមូលដ្ឋាន។ ដំណើរការវិមជ្ឈការទាំងឡាយអាចជួយបង្កើនតួនាទីស្ថាប័នមូល-ដ្ឋាននៅក្នុងការសំរុះសំរួលជំលោះនានាដែលពាក់ព័ន្ធជាមួយនិងធនធានធម្មជាតិដោយមានលទ្ធផលលាយឡំគ្នា។

ករណីសិក្សានៅក្នុងបណ្តាប្រទេសទាំងឡាយនោះបានរកឃើញថាប្រព័ន្ធទាំងឡាយសំរាប់ការពិភាក្សាច្បាប់គឺមានការខ្វះចន្លោះយ៉ាងធំ ឬវាពុំត្រូវបានគេប្រើប្រាស់ដោយអ្នកស្រុកនៅតំបន់ជនបទនោះទេ។ វាមានភាពរួមគ្នាមួយសំរាប់អំ-ណាចប្រតិបត្តិនិងអំណាចតុលាការក្នុងការផ្ទេរអោយមនុស្សដដែលឬគណៈកម្មការមួយឆ្លងតាមលទ្ធផលនៃការធ្វើវិមជ្ឈការនេះ។ ជាឧទាហរណ៍ អ្នកដឹកនាំភូមិ

ដែលជាអ្នកសំរុះសំរួលជាប្រពៃណីនៃជំលោះមូលដ្ឋាននោះអាចទទួលបាននូវអំណាចប្រតិបត្តិធំជាងមុននៅពីក្រោយនៃការធ្វើវិមជ្ឈការនេះ។ ការរៀបចំរបៀបនេះបន្សល់ទុកអោយអ្នកស្រុកនូវមធ្យោបាយដែលគ្មានប្រសិទ្ធិភាពនៅពេលដែលពួកគេចង់ធ្វើការតវ៉ាអំពីការធ្វើតួនាទីជាអ្នកដឹកនាំភូមិ។ ករណីនេះបានកើតមានឡើងនៅក្នុងការសិក្សាក្នុងខេត្តភូ ថូប្រទេសវៀតណាម។ នៅក្នុងស្ថានភាពផ្សេងមួយទៀតនៅពេលដែលប្រជាជនមូលដ្ឋានមានជំលោះជាមួយអ្នកមកពីខាងក្រៅដូចជាក្រុមហ៊ុនឯកជនដែលរដ្ឋបាលអាចមានលទ្ធភាពការពារផលប្រយោជន៍របស់សហគមន៍នោះ ពេលនោះពួកគេមានការពេញចិត្តជាមួយនិងលទ្ធផលដែលទទួលបានមកនោះ។ ករណីដូចគ្នានេះបានកើតមាននៅក្នុងខេត្តរតនៈគីរីដែលអាជ្ញាធរស្រុកបានទទួលយ៉ាងជោគជ័យនូវប្រាក់សងការខូចខាតពីក្រុមហ៊ុនដូង-ប្រេងដែលបានបំផ្លាញទ្រព្យសម្បត្តិរបស់អ្នកស្រុក។

គួរអោយកត់សំគាល់ផងដែរថាករណីសិក្សាពុំបានរកឃើញភស្តុតាងរបស់បុគ្គលឬសហគមន៍នានាដែលប្រើតុលាការឯករាជ្យដើម្បីដោះស្រាយជំលោះនានាពាក់ព័ន្ធទៅនិងធនធានធម្មជាតិ។ សាខាប្រតិបត្តិថ្នាក់ខ្ពស់ជាងនេះទាំងឡាយគឺជាមធ្យោបាយនៃធនធានតែមួយគត់ដែលអាចចូលទៅដល់បាន។ទោះបីជាប្រទេសដែលបានសិក្សាទាំងអស់មានតុលាការក៏ដោយក្តី ប៉ុន្តែជាធម្មតាតុលាការនោះតែងតែនៅឆ្ងាយពីការឈោងចាប់ដល់របស់ប្រជាជននៅជនបទដែលជាអ្នកខ្វះខាតថវិការដើម្បីធានានូវភាពជាតំណាងស្របច្បាប់របស់ពួកគេ។ ដូចជាករណីនៅក្នុងប្រទេសចិនដែលមានអ្នកច្បាប់តំនាងអោយប្រយោជន៍សាធារណៈមានតែបីបួននាក់ប៉ុណ្ណោះ (Brettell, 2001 )។ នៅទីកន្លែងផ្សេងៗទៀតអ្នកស្រុកត្រូវបានបង្អាក់ស្មារតីពីការប្រើប្រាស់ប្រព័ន្ធតុលាការ ព្រោះដោយសារតែមានអំពើពុករលួយយ៉ាងរីករាលដាលនៅទីនោះ។

ដើម្បីជំនះបាននូវកង្វះខាតការតំរង់ទិសដ៏ឯករាជ្យនៃជំលោះបរិស្ថាននានានោះ--និងផលវិបាកទាំងឡាយរបស់វា--យ៉ាងហោចណាស់មានសកម្មភាពជួរមុខពីរដែលតំរូវអោយធ្វើ។ ទីមួយ ត្រូវមានកិច្ចប្រឹងប្រែងដើម្បីពង្រឹងនិងដើម្បីគាស់រំលើងចេញនូវអំពើរពុករលួយនៅក្នុងប្រព័ន្ធច្បាប់នៃបណ្តាប្រទេសដែលបានសិក្សានោះនឹងផ្តល់ផលប្រយោជន៍អោយសហគមន៍ជនបទដែលកំពុងស្វែងរកនូវការការ

ពារសិទ្ធិពាក់ព័ន្ធនិងធនធានធម្មជាតិ។ ទីពីរ ការយល់ដឹងរបស់ប្រជាជនអំពីប្រព័ន្ធច្បាប់និងការដែលអាចចូលទៅប្រើប្រាស់បានសំរាប់ពួកគេគឺត្រូវតែពង្រឹងស្របគ្នា។

សកម្មភាពនៃការត្រួតពិនិត្យនិងការវាយតំលៃដែលមានលក្ខណៈជាប្រពន្ធ័គឺជាផ្នែកដ៏មានសារៈសំខាន់មួយក្នុងការជំរុញអោយមានការបើកមុខអំពើពុករលួយនិងចងភ្ជាប់រដ្ឋាភិបាលមូលដ្ឋានអោយមានការទទួលខុសត្រូវក្នុងការធ្វើតួនាទីល្អជាទូទៅ។ជាអកុសលនៅក្នុងករណីសិក្សានានា សកម្មភាពដើម្បីដាក់បញ្ចូលក្តីកង្វល់និងបទពិសោធន៍នៃការអនុវត្តន៍ទាំងឡាយរបស់សហគមន៍នៅក្នុងរដ្ឋាភិបាលថ្នាក់ខ្ពស់នោះគឺមានភាពរប៉េះរប៉ោះនិងមានការបាត់បង់យ៉ាងខ្លាំង។ ទោះបីជាមានការពាក់ព័ន្ធជាមួយនិងកម្មវិធីម្ចាស់មូលនិធិក៏ដោយសកម្មភាពទាំងនេះត្រូវបានគេបំភ្លេចចោលដោយសារថាខ្វះខាតថវិការនិងការបង្កើតនិតិក្រមនានា។ ជានិច្ច-កាលប្រជាជនមូលដ្ឋានមានលទ្ធភាពគ្រប់គ្រាន់ក្នុងការរួមចំណែកត្រួតពិនិត្យនិងវាយតំលៃប៉ុន្តែពួកគេត្រូវការមធ្យោបាយងាយស្រួលនិងដែលអាចទុកចិត្តបាននៅក្នុងការប្រមូលនិងបញ្ជូនពត៌មានទាំងឡាយនោះ។ គំនិតផ្តួចផ្តើមនានាក្នុងការត្រួតពិនិត្យនិងការវាយតំលៃគួរត្រូវបានការគាំទ្រដោយរដ្ឋាភិបាលម្ចាស់មូលនិធិអង្គការសាសនានិងអ្នកដែលមានការចាប់អារម្មណ៍ទាំងឡាយ។

## កិច្ចសហប្រតិបត្តិការរវាងទីភ្នាក់ងារនិងយុត្តាធិការ

ការធ្វើវិមជ្ឈការគឺមិនត្រឹមតែផ្លាស់ប្តូរទំនាក់ទំនងនៃការទទួលខុសត្រូវរវាងរដ្ឋាភិបាលមូលដ្ឋាននិងរដ្ឋាភិបាលមជ្ឈឹមឬរវាងអាជ្ញាធរមូលដ្ឋាននិងប្រជាជនសហគមន៍ប៉ុណ្ណោះទេ ការធ្វើវិមជ្ឈការក៏ផ្លាស់ប្តូរផងដែរនូវតួនាទីនិងការទទួលខុស ត្រូវរបស់មន្ទីរក្រសួងនិងការផ្តល់អោយនូវការទំនាក់ទំនងការទទួលខុសត្រូវក្នុងចំណោមភូមិ ឃុំនិងស្រុកនានានិងក្នុងចំណោមទីភ្នាក់ងារទាំងនោះផងដែរ។ ទំនាក់ទំនងថ្មីអស់ទាំងនេះត្រូវមានការអនុវត្តន៍យ៉ាងពិសេសសំរាប់ថាតើគួរអោយមានរបៀបគ្រប់គ្រងធនធានធម្មជាតិដោយវិធីណា។ ព្រោះឥទ្ធិពលនៃការធ្វើអាជីវកម្មធនធានធម្មជាតិនានាតែងតែហួរឆ្លងកាត់អាណត្តិនៃយុត្តាធិការនិងទីភ្នាក់ងារទាំងអស់នោះ។ ករណីសិក្សាបានរកឃើញថាដំណើរការវិមជ្ឈការទាំងឡាយពុំបាន

អោយភាពចាំបាច់ក្នុងការដោះស្រាយប្រព័ន្ធការគ្រប់គ្រងអេកូឡូស៊ីបានគ្រប់គ្រាន់ដូចដែលពីមុនមកធ្លាប់មាននោះទេ ជាងនោះទៅទៀតក្នុងការប្រព្រឹត្តទៅនៃកំនែទំរង់វិមជ្ឈការ អ្នកតាក់តែងច្បាប់ទាំងឡាយតែងតែបំភ្លេចឱកាសដើម្បីបង្កើតអោយមានការគ្រប់គ្រងអោយល្អប្រសើជាងមុននូវប្រព័ន្ធអេកូឡូស៊ី។

នៅក្នុងករណីខ្លះ អ្នកតាក់តែងច្បាប់ទាំងឡាយបានផ្តល់ការទទួលខុសត្រូវសំរាប់ការគ្រប់គ្រងធនធានធម្មជាតិដល់អ្នកនៅថ្នាក់ក្រោមនៃឋានានុក្រមរដ្ឋបាលនយោបាយរបស់ខ្លួនដោយពុំបានពង្រឹង(ឬសូម្បីតែការបង្កើត)ស្ថាប័នកំរិតកណ្តាលដែលចាំបាច់សំរាប់ការគ្រប់គ្រងដ៏មានប្រសិទ្ធិភាពនៃការគ្រប់គ្រងមាត្រដ្ឋានអេកូឡូស៊ីនោះទេ។ តួយ៉ាង នៅក្នុងសង្កាត់បាវឆាននៃខេត្តយុនណានប្រទេសចិន ភាពទទួលខុសត្រូវដ៏ជាក់លាក់សំរាប់ការគ្រប់គ្រងធនធានធម្មជាតិ ដូចជាការអភិរក្សទឹកនិងព្រៃឈើត្រូវបានគេប្រគល់អំណាចអោយទៅរចនាសម្ព័ន្ធរដ្ឋបាលនយោ-បាយថ្នាក់ក្រោមបំផុត--នៃទីប្រជុំជន(Zuo Ting និង Xu, ២០០១)។ នៅក្នុងកំរិតនេះអ្នកគ្រប់គ្រងធនធានទាំងឡាយមិនត្រឹមតែខ្វះបច្ចេកទេសជាមូលដ្ឋានសំរាប់ការថែរក្សាបរិស្ថានដ៏ឈ្លាសវៃនោះទេ ពួកគេថែមទាំងគ្មានទទួលបានការលើកទឹកចិត្តដើម្បីយកចិត្តទុកដាក់ទៅលើការខូចខាតពីការធ្វើអាជីវកម្មធនធាននិងពីសកម្មភាពឧស្សាហកម្មទាំងនោះផងទេ។ ជំលោះនានាគឺកំពុងកើនឡើងរវាងភូមិក្បែរខាងនិងទីប្រជុំជនទាំងឡាយដែលមានទីតាំងនៅខាងក្រោមស្ទឹងហើយវាបានទទួលរងផលប៉ះពាល់ពីការបំពុល សំណឹកនិងកករល្បាប់ដែលបង្ករឡើងដោយសកម្មភាពអភិវឌ្ឍន៏ទាំងឡាយនៅខាងលើខ្សែទឹក។ បញ្ហាទាំងឡាយនៅបាវឆានគឺជាបដិរូបនៃគំលាតកិច្ចសហប្រតិបត្តិការរវាងអន្តរយុត្តាធិការឬអន្តរក្រសួងទូទាំងប្រទេសចិន(Jahiel, ១៩៩៨)។ បណ្តាញក្រៅផ្លូវការទាំងនោះឬការចូលរួមជាសម្ព័ន្ធភាពទាំងនោះនៃរដ្ឋាភិបាលមូលដ្ឋានដើម្បីកំនត់និងអនុវត្តន៏គោលបំនងបរិស្ថានរួមអាចជួយបង្កើននូវស្ថានភាពនេះអោយល្អ។ ដូចនៅក្នុងបណ្តាប្រទេសផ្សេងៗទៀតដែរការបង្កើតឡើងនូវស្ថាប័នថ្មីសំរាប់ការគ្រប់គ្រងអេកូឡូស៊ីជាក់លាក់ណាមួយដូចជា អាងទន្លេនោះគឺពិតជាមានលទ្ធភាពអាចធ្វើទៅបានហើយអាចមានប្រសិទ្ធិភាពប្រសិនបើស្ថាប័នថ្មីៗនេះសំរបសំរួលយ៉ាងជិតស្និតជាមួយនិងអាជ្ញាធរមូលដ្ឋានទាំងឡាយ(ប្រជុំជនឬស្រុកនិងភូមិ)។

នៅក្នុងករណីសិក្សាជាច្រើន ទំរង់ផ្សេងទៀតនៃជំលោះអន្តរទីភ្នាក់ងារតែង កើតឡើងនៅកំរិតថ្នាក់មូលដ្ឋាន។ ជួនកាលទៀតអាណត្តិនានា ទិសដៅ និងយុទ្ធវិធីទាំងឡាយរបស់ខ្សែរយៈទីភ្នាក់ងារបានត្រូវគេព្រងើយកន្តើយជាមួយនិងចំណាត់ថ្នាក់អត្ថិភាពផ្អែកជីវភាពរបស់សហគមន៍មូលដ្ឋានទាំងឡាយ។ ស្ថាប័នក្នុងស្រុកនានាដូចជាក្រុមប្រឹក្សាភូមិនិងអាជ្ញាធរឃុំត្រូវបានផ្ចាញ់ផ្ចាលគ្នាឬបំផ្លាញដោយកិច្ចប្រឹងប្រែងផ្ទុយគ្នានៃខ្សែរយៈក្រសួង។ តួយ៉ាង នៅក្នុងប្រទេសវៀតណាមនិងឡាវ បទបញ្ញត្តិទីផ្សារដែលដាក់ឡើងដោយរដ្ឋាភិបាលមជ្ឈឹមគឺនៅតែខ្លាំងហើយជះឥទ្ធិពលផ្ទាល់ដល់ថាមវន្តនៃការធ្វើវិមជ្ឈការ។ កូតាផលិតកម្មស្បៀងគឺត្រូវបានជំរុញពីថ្នាក់ជាតិចុះទៅថ្នាក់ភូមិជាមួយនិងភ្នាក់ងារផ្សព្វផ្សាយដែលកំពុងចែកចាយគ្រាប់ពូជ កូនឈើ ជីធម្មជាតិ ថ្នាំសំលាប់សត្វល្អិត និងតិណឃាតទាំងឡាយ។ ប្រព័ន្ធនេះគឺមានភាពទំនាស់ជាមួយនិងបទបញ្ញត្តិដែលជំរុញការចូលរួមពីមូលដ្ឋាននៅក្នុងផែនការប្រើប្រាស់ដីធ្លីនិងការបង្កើនការរួមវិភាគទានរបស់មូលដ្ឋាននៅក្នុងផែនការអភិវឌ្ឍន៍នានានោះផងដែរ។

នៅក្នុងខេត្តធូ ធានហូប្រទេសវៀតណាម អាជ្ញធរមូលដ្ឋានបានធ្វើយុទ្ធនាការដ៏ធំមួយរបស់រដ្ឋាភិបាលដើម្បីអោយប្រជាជនផលិតស្ករអំពៅសំរាប់ក្រុមហ៊ុនបណ្តាក់ទុនវៀតណាម-តៃណ្ចាដែលនៅខាងក្រោមខ្សែទឹក។ អាជ្ញាធរ ឃុំនិងស្រុកទាំងឡាយបានបញ្ចុះបញ្ចូលអោយគ្រួសារនៅឃុំហុង ហាចំនួន៨០ ភាគរយដាំអំពៅ។ ទោះជាយ៉ាងណា វិនាសកម្មទឹកជំនន់នៅឆ្នាំ១៩៩៩ បានបំផ្លាញទិន្នផលអស់ចំនួនពាក់កណ្តាល ហើយក្រុមហ៊ុនបានលុបចោលនូវការបញ្ជាទិញពីអ្នកដែលនៅសល់។ ចាប់តាំងពីពេលនោះមកដីដំណាំអំពៅបានក្លាយទៅជាបញ្ហាក្នុងការរើបខ្លួនឡើងវិញរបស់ភូមិនៅពេលដែលវាទាមទារអោយមានការចំណាយកំលាំងច្រើនដើម្បីប្រែក្លាយដីអំពៅទៅជាដីស្រែនិងដំណាំផ្សេងៗវិញ (Beckman et al., ២០០១)។ ជាផលវិបាកនៃបទពិសោធន៍នេះអាជ្ញាធរឃុំទាំងឡាយបានចាប់ផ្តើមប្រុងប្រយ័ត្នចំពោះភាពគ្រោះថ្នាក់នៃការផ្លាស់ប្តូររបបចិញ្ចឹមជីវិត និងការភ្ជាប់ទៅលើទីផ្សារដែលអាចបាត់ស្រមោលភ្លាមៗនៅក្នុងមូលដ្ឋាន។ ដូចគ្នានេះដែរនៅខេត្តលួងប្រា បាងប្រទេសឡាវ អ្នកដឹកនាំនយោបាយ អ្នកផ្សព្វផ្សាយនិងអភិវឌ្ឍន៍ ទាំងឡាយបានស្នើរអោយប្រជាជនផលិតរបស់ដើម្បីនាំចេញហើយក្នុង

ពេលដែលទីផ្សារដួលរលំនោះកសិករបានត្រូវគេបន្សល់ទុកនូវប្រាក់ចំនូលមិនគ្រប់គ្រាន់ដើម្បីបំពេញនូវសេចក្តីត្រូវការជាមូលដ្ឋានរបស់ពួកគេ។

ការប្រឈមមុខដ៏ធំបំផុតមួយនៃកិច្ចប្រឹងប្រែងធ្វើវិមជ្ឈការទាំងឡាយគឺការបង្កប់នូវក្របខណ្ឌ័មួយដែលជំរុញគោលដៅទូទៅរបស់ជាតិក្នុងការធ្វើសមាហរណកម្មរដ្ឋបាលនិងសេដ្ឋកិច្ច គុណភាពបរិស្ថាននិងការបង្កើនប្រាក់ចំណូលនៅពេលដែលមានការអនុញ្ញាតិភាពបត់បែនបានយ៉ាងគ្រប់គ្រាន់នៃការអនុវត្តន៏នៅក្នុងមូលដ្ឋានដើម្បីបំពេញបាននូវលក្ខ័ណ្ឌដ៏ស្មុគ្រស្មាញនានារួមទាំងភាពចំរុះនៃវប្បធម៏និងអេកូឡូស៊ីនៅក្នុងតំបន់។ ភស្តុតាងចេញពីករណីសិក្សាបានស្នើរអោយមានមធ្យោ-បាយដែលប្រកបដោយជោគជ័យមួយក្នុងការបំពេញនូវគោលបំនងទាំងនេះដោយត្រូវអោយមានការស៊ីចង្វាក់គ្នានូវផលប្រយោជន៏ចំនេះដឹងមូលដ្ឋាននោះគឺការនែនាំទីភ្នាក់ងាររដ្ឋាភិបាលមជ្ឈឹមអោយក្លាយទៅជាទីប្រឹក្សាបច្ចេកទេសសំរាប់អាជ្ញាធរមូលដ្ឋានទាំងឡាយដែលជាប់ឆ្នោតដោយលទ្ធិប្រជាធិបតេយ្យ។ នៅក្នុងលក្ខណៈជាដៃគូដ៏ជោគជ័យមួយ ខ្សែរយៈទីភ្នាក់ងារនិងសេវាផ្សព្វផ្សាយទាំងអស់គួរផ្តល់នូវពត៏មានការគាំទ្របច្ចេកទេសដែលអាចឆ្លើយតបបានចំពោះកង្វល់និងសេចក្តីត្រូវការនានាដែលបង្ហាញដោយប្រជាជនមូលដ្ឋាននិងអ្នកតំណាងស្ថាប័នមូលដ្ឋានរបស់ពួកគេ។

## ការចលនាសហគមន៏

សក្តានុពលនៃដំណើរការវិមជ្ឈការដើម្បីជំរុញការអភិវឌ្ឍន៏បរិស្ថាននិងសង្គមប្រកបដោយនិរន្តភាពនោះគឺមិនមែនត្រឹមតែជាប្រតិកម្មនៃ “អ្នកផ្តល់អោយ” ត្រូវធ្វើសកម្មភាពបែបណានោះទេដូចដែលបានពិពណ៌នាខាងលើស្រាប់។ សក្តានុពលនៃការធ្វើវិមជ្ឈការដែលបំពេញបាននូវគោលបំនងទាំងនេះគឺត្រូវផ្អែកទៅលើប្រតិកម្មនៃ “អ្នកចង់បាន” គឺប្រជាជនដែលស្ថិតនៅក្នុងគោលដៅនោះត្រូវធ្វើសកម្មភាពតបវិញយ៉ាងដូចម្តេច។

ករណីសិក្សាបានរកឃើញថាសហគមន៏ទាំងឡាយដែលបញ្ចេញសំលេងទាមទារយ៉ាងច្បាស់លាស់សំរាប់ភាពជាតំណាងនិងការសំដែងតួនាទីល្អនៅក្នុងរដ្ឋាភិបាល ហើយនិងការប្រមូលចងក្រងជុំវិញគោលបំនងនិងទិសដៅរួមនានានោះគឺ

ជាការយកចំនេញដ៏ប្រសើរបំផុតពីដំណើរការនៃការធ្វើវិមជ្ឈការ។ ផ្ទុយមកវិញ ទ្រព្យសម្បត្តិផ្នែកនយោបាយទាំងនេះគឺជាលទ្ធផលនៃភាពខ្លាំងរបស់សង្គមដ៏ជាក់ច្បាស់នៅក្នុងបណ្តាសហគមន៍(ភាពអោនលំទោនតាមនៃប្រជាពលរដ្ឋ ទំនាក់ទំនងល្អរវាងបុគ្គលនិងបុគ្គល រវាងក្រុមគ្រួសារ ហើយនិងមានការចែករំលែកនូវជំនឿនិងតំលៃនានា)ដែលគេតែងតែហៅថាជា *ធនធានសង្គម*។ ធនធានសង្គមអាចកើតមានឡើងនៅក្នុងសហគមន៍ដូចដែលមានក្នុងទឹកន្លែងសិក្សានៃខេត្តធូធានហ្វ។ នៅទីនោះក្រុមគ្រួសារទាំងអស់បានប្រមូលចងក្រងគ្នាដើម្បីជួយគ្នាទៅវិញទៅមកបន្ទាប់ពីមានគ្រោះថ្នាក់ទឹកជំនន់ហើយនៅក្នុងការធ្វើយ៉ាងដូច្នេះ ពួកគេបានពង្រឹងដំណោះស្រាយរបស់ពួកគេដើម្បីកសាងទ្រព្យធនសហគមន៍របស់ពួកគេឡើងវិញ ហើយបានបញ្ចេញនូវសំលេងទាមទាររួមទៅដល់មេដឹកនាំឃុំ។ ធនធានសង្គមអាចត្រូវបានកសាងរវាងសហគមន៍ផងដែរដូចនៅភូមិភាគខាងជើងនៃប្រទេសថៃ។ នៅទីនោះសហគមន៍បានបង្កើតនូវបណ្តាញការងារនិងអង្គការទាំងឡាយសំរាប់មូលហេតុនៃបរិស្ថាននិងការអភិវឌ្ឍន៍ដូចជាការការពារតំបន់ទីជំរាលរងទឹកភ្លៀងជាដើម។ កិច្ចសហប្រតិបត្តិការឆ្លងព្រំប្រទល់នយោបាយនិងសង្គមនេះត្រូវបានជួយក្នុងការជំរុញកិច្ចអភិរក្សអេកូឡូស៊ី។ នៅក្នុងករណីនេះរដ្ឋាភិបាលបានបង្កើតនូវការរួមវិភាគទានដោយផ្តល់នូវទីតាំងផ្នែកនយោបាយសំរាប់សហគមន៍ដើម្បីបង្កើតក្រុមផលប្រយោជន៍នានាដែលអាចពង្រឹងបាននូវភាពរឹងប៉ឹងផ្នែកជីវ-ភាពរបស់ពួកគេ។

ជាការបន្ថែមនូវការពង្រឹងលទ្ធភាពបរិស្ថានជាមូលដ្ឋាន តំបន់ទាំងឡាយដែលមានធនធានសង្គមទាបគឺត្រូវការជំនួយបន្ថែមដើម្បីបង្កើនឱកាសការធ្វើវិមជ្ឈការអោយបានជោគជ័យ។ ជាបឋមគេត្រូវការធនធានមនុស្សបន្ថែមទៀតនៅក្នុងទំរង់នៃការបង្កើនការសំរបសំរួលនិងការផ្សព្វផ្សាយសហគមន៍ដោយទីភ្នាក់ងារដែលជាប់ពាក់ព័ន្ធនានាឬដោយភាគីទីបី ដូចជាអង្គការមិនមែនរដ្ឋាភិបាលនានាជាដើម។ ទោះជាយ៉ាងណាក៏ដោយបទពិសោធន៍នៅមូលដ្ឋានបន្ថែមទៀតការត្រួតពិនិត្យ និងការវាយតំលៃគឺជាការចាំបាច់ណាស់ទាក់ទងទៅនិងវាសនានៃកំនែទំរង់វិមជ្ឈការនៅក្នុងតំបន់ដែលមានភាពចលាចលសង្គមនិងភាពដែលមានការបែកបាក់សង្គមខ្ពស់ដើម្បីឈានទៅរកសេចក្តីសន្និដ្ឋានជាស្ថាពរមួយ។

បទពិសោធន៍មកដល់ពេលនេះបានស្នើឡើងនូវមធ្យោបាយដ៏សមស្របនានាដែលអាចអភិវឌ្ឍន៍ធនធានសង្គមតាមរយៈការគាំទ្រពីអ្នកខាងក្រៅទាំងឡាយឬពីគំនិតផ្តួចផ្តើមរបស់សមាជិកសហគមន៍។ បញ្ហាអស់ទាំងនេះរួមមានៈ ការពង្រឹងសមត្ថភាពសហគមន៍ដើម្បីធ្វើអន្តរកម្មជាមួយរដ្ឋាភិបាលក្នុងស្រុក ដូចជាកិច្ចពិ-គ្រោះយោបល់អោយបានញឹកញាប់បំផុតជាមួយពហុភាគីដ៏មានខ្លឹមសារ ការលើកទឹកចិត្តការភ្ជាប់ទំនាក់ទំនងគ្នាយ៉ាងទូលំទូលាយនៅក្នុងចំណោមក្រុមការងារសង្គមទាំងឡាយ ដូចជាបណ្តាញទីជំរាលទឹករងភ្លៀង ក្រុមអ្នកប្រើប្រាស់ទឹកនិងក្រុមអ្នកគ្រប់គ្រងព្រៃឈើសហគមន៍ ហើយការបង្កើនគោលនយោបាយតំលាភាពកម្មវិធីនិងគំរោងនានាដើម្បីបង្កើនទំនុកចិត្តនិងជំនឿជឿជាក់នៅក្នុងស្ថាប័នរដ្ឋា-ភិបាលទាំងឡាយ។

## IV. អនុសាសន៍

គ្មានគំរូអភិបាលកិច្ចដ៏សាមញ្ញណាមួយ(ទាំងបែបមជ្ឈឹម បែបវិមជ្ឈការឬ បែបឯកជនទូបនីយកម្ម)ដែលអាចធ្វើការសន្យាតែម្នាក់ឯងក្នុងបញ្ហានិរន្តភាពនៃបរិ-ស្ថាននិងការធ្វើអោយមានសុន្តិសុខផ្នែកជីវភាពរបស់តំបន់ខ្ពង់រាបនោះបានទេ។ ប៉ុន្តែករណីដែលបានរកឃើញពីការសិក្សានេះបានស្នើឡើងអំពីវិធីសាស្រ្តនៃការធ្វើវិមជ្ឈការមួយដើម្បីធ្វើផែនការអភិវឌ្ឍន៍និងការគ្រប់គ្រងធនធានធម្មជាតិដោយបានរកឃើញថាវាត្រូវតែពឹងផ្អែកទៅលើលំដាប់ថ្នាក់ច្រើនយ៉ាងនៃការធ្វើសេចក្តីសំរេចចិត្តនិងទំរង់ពហុគុណទាំងឡាយនៃការទទួលខុសត្រូវពីលើចុះក្រោមនិងពីក្រោមឡើងទៅលើនិងការសំរបសំរួលទូលំទូលាយអាចប្រកាន់បាននូវការសន្យាដ៏ធំធេងក្នុងការធ្វើអោយសំរេចបាននូវគោលបំនងទាំងនេះ។ ចុងក្រោយបង្អស់ការធ្វើវិមជ្ឈការគឺជាដំណើរការច្រំដែលៗហើយដែលលក្ខ័ណ្ឌទាំងឡាយអាចវិវឌ្ឍន៍បានទៅតាមពេលវេលាតែមួយគត់។ ប្រសិនបើរដ្ឋាភិបាលទាំងឡាយនៅរង់ចាំរហូតទាល់តែមានអ្វីៗគ្រប់បែបយ៉ាងនោះការធ្វើវិមជ្ឈការប្រហែលជាមិនអាចកើត

មានឡើងបាននោះទេហើយផលប្រយោជន៍ជាច្រើនក្នុងការបង្កើនអាជ្ញាធរនៃការធ្វើសេចក្តីសំរេចចិត្តមូលដ្ឋានក៏ពុំត្រូវបានក្លាយជាការពិតដែរ។

អនុសាសន៍ទាំងឡាយដូចខាងក្រោមនេះបានបញ្ចូលនូវជំហានជាច្រើននៅក្នុងដំណើរការដែលរដ្ឋាភិបាល សហគមន៍និងអ្នកដែលមានការជាប់ពាក់ព័ន្ធទាំងអស់អាចប្រកាន់យកដើម្បីអភិវឌ្ឍន៍នូវប្រព័ន្ធគ្រប់គ្រងបែបវិមជ្ឈការដ៏សមរម្យនិងរឹងមាំមួយសំរាប់ការគ្រប់គ្រងធនធានធម្មជាតិ។ ដូចដែលបញ្ជាក់ពីខាងដើមមកហើយ គោលបំនងបរិស្ថាន ជីវភាពរស់នៅនិងសមភាពសង្គមគឺមិនមែនជាហេតុផលចាំបាច់នៃអត្ថិភាពរបស់រដ្ឋាភិបាលទាំងឡាយសំរាប់ការធ្វើវិមជ្ឈការនោះទេ។ ការកាត់បន្ថយបន្ទុកសារពើពន្ធរបស់រដ្ឋាភិបាលមជ្ឈឹម ការពង្រីកការគ្រប់គ្រងនៃរដ្ឋការកណ្តាល(ដូចជានៅក្នុងការបំបែកធាតុ)ឬការបង្កើននូវសុពលភាពនៃរដ្ឋបាលមូលដ្ឋានអាចជាកំលាំងចលករនៃការធ្វើវិមជ្ឈការ។ ទោះជាយ៉ាងណាក៏ដោយដូចដែលមានក្នុងស្ថានភាពបច្ចុប្បន្ននៃតំបន់ខ្ពង់រាបទាំងឡាយគឺវាមានសារៈសំខាន់ណាស់ដែលកំណែទំរង់វិមជ្ឈការទាំងឡាយពុំបានធ្វើអោយមានភាពរិចរឹលបរិស្ថាននិងភាពក្រីក្រកាន់តែខ្លាំងឡើងថែមទៀតនោះ។ទៅតាមលទ្ធភាពដែលអាចធ្វើទៅបានកំណែទំរង់វិមជ្ឈការទាំងឡាយគួរត្រូវបានគេរចនាឡើងដើម្បីបង្កើនប្រព័ន្ធអេកូឡូស៊ីនិងទិដ្ឋភាពផ្នែកជីវភាពនានារបស់អ្នកស្រុកនៅតំបន់ខ្ពង់រាប។ សំនើរទាំងឡាយដូចខាងក្រោមនេះអាចជួយលើកិច្ចការទាំងនេះបាន។

**អនុសាសន៍នានាសំរាប់អ្នកតាក់តែងច្បាប់ជាតិទាំងឡាយ:**

- ❖ បង្កើតឬពង្រឹងនូវអាជ្ញាធរមូលដ្ឋានដែលបានជាប់ឆ្នោតរួចហើយ ហើយធ្វើទៅតាមទីកន្លែងដែលអាចធ្វើទៅបាន ត្រូវកំនត់ចំណាត់ថ្នាក់អត្ថិភាពមូលដ្ឋាននានានៅក្នុងក្របខ័ណ្ឌគោលនយោបាយថ្នាក់ជាតិមួយដើម្បីការអភិវឌ្ឍន៍ប្រកបដោយនិរន្តភាព។
- ❖ ត្រូវអោយប្រាកដថាគោលនយោបាយទាំងនោះគឺត្រូវមានភាពរឹងមាំនិងប្រកាសអំពីតួនាទីនិងការទទួលខុសត្រូវទាំងអស់អោយបានច្បាស់លាស់ ជាពិសេសរវាងអាជ្ញាធរមូលដ្ឋានដែលបានជាប់ឆ្នោតហើយនិងខ្សែបណ្តាញទីភ្នាក់ងារនានា។

- រៀបចំនូវជំហានពិសេសទាំងឡាយនៅក្នុងដំណើរការវិមជ្ឈការដែលបង្កើន សំលេងអនុក្រុមដែលគេតែងតែផាត់ចោលជាប្រពៃណី តួយ៉ាងដូចជាក្រុម ស្ត្រីនិងគ្រួសារក្រីក្រនានា ហើយកិច្ចប្រឹងប្រែងនេះអាចរួមទាំងការបំរុងទុក កៅអីខ្លះនៅក្នុងជួរគណកម្មការដែលធ្វើសេចក្តីសំរេចចិត្តនៅថ្នាក់មូលដ្ឋាន ឬដំណើរការពិគ្រោះយោបល់នានាដែលធ្វើឡើងដោយឡែកៗពីគ្នាហើយ ដែលអាចសមរម្យទៅនិងសេចក្តីសំរេចចិត្តដ៏ទូលំទូលាយរបស់សហគមន៍ មូលដ្ឋាន។
- ផ្តល់ការទទួលខុសត្រូវនានាសំរាប់ផែនការប្រើប្រាស់ដីធ្លីនិងផែនការអភិវ-ឌ្ឍន៍ទៅដល់អ្នកនៅថ្នាក់ក្រោមទាំងឡាយហើយសមស្របទៅតាមមាត្រដ្ឋាន នៃធនធានដើម្បីទទួលបានផលប្រយោជន៍ពីចំណងសង្គម ស្មារតីនៃសហ-គមន៍ និងចំណេះដឹងមូលដ្ឋានទាំងឡាយ។
- នៃនាំឡើងវិញដល់ទីភ្នាក់ងារផ្សព្វផ្សាយទាំងឡាយដើម្បីអោយពួកគេផ្តល់នូវ សេវាកម្មនានាដល់ប្រជាជនមូលដ្ឋានក្នុងការឆ្លើយតបនិងការព្រួយបារម្ភនិង សេចក្តីត្រូវការនានាដែលបញ្ចេញអោយដឹងផ្ទាល់ពីប្រជាជននិងអ្នកតំណាង មូលដ្ឋានទាំងឡាយរបស់ពួកគេ។
- ត្រូវធ្វើអោយប្រាកដថាអាជ្ញាធរនានាកើតមានឡើងដោយមានភាពសម ស្របទៅនិងមាត្រដ្ឋានអេកូឡូស៊ី(ឧទា.តំបន់ទីជំរាលរងទឹកភ្លៀង)ដើម្បីធ្វើ ការប៉ាន់ប្រមាណនិងលំនាំនៃការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ីនានានិងការវាយ តំលៃហេតុប៉ះពាល់បរិស្ថាននៃសកម្មភាពអភិវឌ្ឍន៍នានា។ សំរបសំរួលការ ងាររបស់ស្ថាប័នទាំងនេះជាមួយនិងលំដាប់នានារបស់រដ្ឋាភិបាលរួមទាំង ក៏រិតសហគមន៍មូលដ្ឋានផងដែរ។
- ពង្រឹងឬបង្កើនល្បឿននៃការបង្កើតប្រព័ន្ធច្បាប់មួយដែលមានភាពសេរីពីឥទ្ធិ ពលមកពីខាងក្រៅ ហើយត្រូវបើកចំហរដល់សាធារណៈជន។

## អនុសាសន៍សំរាប់មន្ត្រីថ្នាក់មូលដ្ឋាន

- ត្រូវប្តេជ្ញាចិត្តក្នុងការធ្វើអោយមានតំលាភាពនៅក្នុងការប្រតិបត្តិការផ្សេងៗ និងបើកចំហរពត៌មាននានាដល់សាធារណៈជន(អំពីឱកាសនានាសំរាប់ការ

ចូលរួម ថវិការនិងសេចក្តីសំរេចចិត្តអភិវឌ្ឍន៏ទាំងឡាយ)ជាអត្ថិភាពចំបងមួយ។

- កំនត់នូវគ្រួសារឬក្រុមទាំងឡាយនៅក្នុងសហគមន៏ដែលមានការលំបាកក្នុងការចូលរួមនៅក្នុងដំណើរការពិគ្រោះយោបល់នានាហើយត្រូវប្រឹងប្រែងសំរួលយ៉ាងណាដើម្បីអោយពួកគេបានចូលរួម។

## អនុសាសន៏សំរាប់សហគមន៏

- ត្រូវទាមទារការទទួលខុសត្រូវពីតំណាងរដ្ឋាភិបាលមូលដ្ឋានទាំងឡាយ។
- ប្រមូលផ្តុំគ្នាដើម្បីបញ្ចេញសំលេងនៃគោលបំនងរួមទាំងឡាយសំរាប់ការអភិវឌ្ឍន៏មូលដ្ឋាន។
- កំនត់នូវគ្រួសារឬក្រុមទាំងឡាយនៅក្នុងសហគមន៏ដែលមានការលំបាកក្នុងការចូលរួមនៅក្នុងដំណើរការពិគ្រោះយោបល់នានាហើយត្រូវប្រឹងប្រែងសំរួលយ៉ាងណាដើម្បីអោយពួកគេបានចូលរួម។
- បង្កើតនិងគាំទ្រយន្តការនានាសំរាប់ការត្រួតពិនិត្យយ៉ាងឯករាជ្យពីភាគីទីបីទៅលើអំពើពុករលួយទាក់ទងនិងបរិស្ថាននិងសំរុះសំរួលនូវជំលោះពាក់ព័ន្ធនិងធនធានធម្មជាតិ(ដូចជាបណ្តាញតំបន់ទីជំរាលរងទឹកភ្លៀងនានា) ទៅតាមលទ្ធភាពដែលអាចធ្វើទៅបាន។
- ជំរុញការផ្លាស់ប្តូរជាវិជ្ជមានជាមួយនិងសហគមន៏ផ្សេងៗទៀតដែលទាក់ទងជាមួយបញ្ហាធនធានធម្មជាតិទាំងឡាយហើយដែលជាការព្រួយបារម្ភរួមនៃសហគមន៏។

## អនុសាសន៏សំរាប់អ្នកផ្តល់ជំនួយនិងអង្គការអន្តរជាតិ

- ត្រូវផ្តល់វគ្គបណ្តុះបណ្តាលដល់មេធាវីនិងចៅក្រមទាំងឡាយហើយត្រូវគាំទ្រការបង្កើតក្រុមច្បាប់សំរាប់ផលប្រយោជន៏សាធារណៈទាំងឡាយនៅក្នុងការអនុវត្តន៏នៃច្បាប់បរិស្ថាន។

- គាំទ្រការបង្កើនចំណេះដឹងវិស័យច្បាប់នៅក្នុងសហគមន៍នានា ជាពិសេសផ្តោតទៅលើសិទ្ធិនានាដែលពាក់ព័ន្ធជាមួយនិងការប្រើប្រាស់ធនធានធម្ម-ជាតិ។
- គាំទ្រនូវការអភិវឌ្ឍន៍យន្តការនានាសំរាប់ដំណោះស្រាយជំលោះដោយភាគីទីបីហើយនិងកិច្ចសហប្រតិបត្តិការអន្តរយុត្តាធិការ ដូចជាបណ្តាញតំបន់ទីជំរាលរងទឹកភ្លៀងទាំងឡាយជាដើម។
- គាំទ្រវគ្គបណ្តុះបណ្តាលនិងការលើកកំពស់ការយល់ដឹងនានាសំរាប់ប្រជាពលរដ្ឋទាក់ទងនិងបញ្ហាយេនឌ័រនិងវិធីសាស្ត្រនៃការចូលរួមជាសាធារណៈនានា។
- ផ្តល់មូលនិធិទៅដល់មូលដ្ឋានដើម្បីអោយដំណើរការនៃការធ្វើសេចក្តីសំរេចចិត្តរបស់អ្នកតំណាងនានាអោយមានប្រសិទ្ធិភាព។
- គាំទ្រការពង្រឹងនៃស្ថាប័នទាំងឡាយសំរាប់ការគ្រប់គ្រងនិងការត្រួតពិនិត្យបរិស្ថានហើយនិងជំលោះធនធាននានានៅលើមាត្រដ្ឋានប្រព័ន្ធអេកូឡូស៊ី។

### អនុសាសន៍សំរាប់សកលវិទ្យាល័យនិងអង្គការស្រាវជ្រាវ

- បន្តធ្វើការវាយតំលៃនៃឥទ្ធិពលកំនែទំរង់វិមជ្ឈការលើបញ្ហាជីវភាពរស់នៅរបស់មូលដ្ឋាននិងប្រព័ន្ធអេកូឡូស៊ីទាំងឡាយ។
- ត្រូវធ្វើការជាមួយប្រជាជនមូលដ្ឋានដើម្បីអភិវឌ្ឍន៍កត្តាចង្អុលបង្ហាញនានានៃឥទ្ធិពលបរិស្ថាននិងសង្គមដែលបានមកពីការផ្លាស់ប្តូរគោលនយោបាយនិងស្ថាប័នទាំងឡាយ ហើយដែលអាចគេយកទៅប្រើសំរាប់ការត្រួតពិនិត្យដ៏យូរអង្វែង។

# សេចក្តីបរិយាយបន្ថែម
## និយមន័យនៃវិមជ្ឈការ*

**វិមជ្ឈការ** គឺសំដៅទៅលើទង្វើណាមួយដែលរដ្ឋាភិបាលកណ្តាលផ្ទេរអំណាចនានាទៅដល់អ្នកដើរតួនាទីនិងស្ថាប័ននៅថ្នាក់ក្រោមទៅតាមឋានានុក្រមរដ្ឋបាលនយោបាយថ្នាក់ក្រោម (ឧទា. Mawhood, 1983; Smith, 1985)។ យើងប្រើពាក្យវិមជ្ឈការជាពាក្យសំខាន់ចំបងដែលបានរាប់បញ្ចូលរាល់ទំរង់ទាំងអស់ដូចដែលបានពិពណ៌នានៅទីនេះ។

**វិមជ្ឈការនយោបាយឬវិមជ្ឈការប្រជាធិបតេយ្យ** គឺកើតឡើងនៅពេលដែលអំនាចនិងធនធានទាំងឡាយត្រូវបានផ្ទេរទៅដល់អ្នកតំនាងអាជ្ញាធរនានាដែលមានការទទួលខុសត្រូវពីលើចុះក្រោមចំពោះប្រជាជនមូលដ្ឋាន (ឧទា. Crook និង Manor, 1998; Manor 1999; Agrawal និង Ribot, 1999)។ ដោយការអនុវត្តន៍ អាជ្ញាធរមូលដ្ឋានទាំងឡាយទទួលបានសិទ្ធិអំនាចក្នុងការធ្វើច្បាប់ឬការបង្កើតគោលការណ៍នានា--នៅក្នុងបញ្ញត្តិដែលបានកំរិត។

**សហវិមជ្ឈការឬវិមជ្ឈការរដ្ឋបាល** ពាក់ព័ន្ធនិងការផ្ទេរនៃអំណាចទៅដល់សាខាមូលដ្ឋាននានានៃរដ្ឋការកណ្តាល ដូចជាអនុខេត្ត អ្នករដ្ឋបាល ឬបណ្តាញភ្នាក់ងារក្រសួងបច្ចេក-ទេស (ឧទា. Mawhood, 1983)។ គណកម្មការទទួលខុសត្រូវពីក្រោមឡើងលើទាំងនេះគឺត្រូវតែងតាំងរដ្ឋបាលមូលដ្ឋានដែលជាអ្នកផ្សព្វផ្សាយអោយរដ្ឋការកណ្តាល។

**ការធ្វើវិមជ្ឈការសារពើពន្ធ** គឺជាការធ្វើវិមជ្ឈការផ្នែកខាងថវិការនិងអំនាចនៃការបង្កើនប្រាក់ចំនូលនានា ដែលត្រូវបានកំនត់ដោយអ្នកវិភាគទាំងឡាយថាជាទំរង់ដោយឡែកមួយនៃវិមជ្ឈការ (ឧទា. Wunsch និង Olowun, 1995; Manor, 1999; Crook និង Manor, 1998)។ ប៉ុន្តែទោះជាការផ្ទេរសារពើពន្ធមានសារៈសំខាន់ក៏ដោយក៏ពួកគេបង្កបង្កើតនូវសមាសធាតុកាត់ទទឹងមួយ ទាំងសហវិមជ្ឈការនិងទាំងការធ្វើវិមជ្ឈការនយោបាយជាជាងប្រភេទដោយឡែកមួយទៀត (ឧ.Oyugi, 2000; Agrawal និង Ribot, 1999)។

**ឯកជនូបនីយកម្ម** គឺជាការផ្ទេរអំណាចជាអចិន្ត្រៃយ៍ទៅអោយអង្គភាពដែលមិនមែនជារដ្ឋការណាមួយ រួមទាំងបុគ្គលនានា សាជីវកម្មនានា អង្គការមិនមែនរដ្ឋាភិបាលនានា

។ល។ ទោះបីជាឯកជនូបនីយកម្មតែងតែអនុវត្តន៍នៅក្នុងនាមជាការធ្វើវិមជ្ឈការ ប៉ុន្តែវា មិនមែនជាទំរង់មួយនៃការធ្វើវិមជ្ឈការនោះទេ (Agrawal និង Ribot, 1999 )។

**សហគ្រប់គ្រង** គឺសំដៅទៅដល់ការបង្កើតគោលការណ៍និងការរៀបចំទាំងឡាយក្នុងការគ្រប់គ្រងធនធានធម្មជាតិដែលផ្សំឡើងដោយសហវិមជ្ឈការនិងឯកជនូបនីយកម្ម។ សហគ្រប់គ្រងនេះកើតមានឡើងដោយមានគណៈកម្មការមួយដែលមានលក្ខណៈពាក់កណ្តាលជាការតែងតាំងនិងពាក់កណ្តាលទៀតជាការបោះឆ្នោត។ ការបរិយាយអំពីសហគ្រប់គ្រងគឺជាការរៀបចំបែងចែកអំណាច រវាងខ្សែបណ្តាញក្រសួងទាំងឡាយដែលមានការទទួលខុសត្រូវរបៀបពីលើចុះក្រោមនិងអ្នកតំណាងភូមិឬអ្នកប្រើប្រាស់ធនធានដែលមានការទទួលខុសត្រូវរបៀបពីក្រោមឡើងទៅលើ។

* ដោយលើកលែងផ្នែកចុងក្រោយនេះ និយមន័យទាំងនេះគឺបានដកស្រង់ចេញពី “ការកំនត់វិមជ្ឈការ” ដោយ Jesse C. Ribot, ដែលបានរៀបចំឡើងសំរាប់សន្និសិទស្តីពីការធ្វើវិមជ្ឈការនិងបរិស្ថាននៅ Bellagio, ប្រទេសអ៊ីតាលី ខែកុម្ភៈ២០០២។

## សេចក្តីថ្លែងអំណរគុណ

សហនិពន្ធនៃរបាយការណ៍នេះបានរៀបចំចងក្រងលទ្ធផលនានា រួមទាំងការធ្វើវិភាគតាមតំបន់ ហើយយើងសូមថ្លែងអំណរគុណចំពោះកិច្ចប្រឹងប្រែងដែលមានតំលៃមិនអាចកាត់ថ្លៃបានរបស់ក្រុមនានាដែលបានផលិតចេញនូវរបាយការណ៍ករណីសិក្សានេះ។ អ្នកនិពន្ធយើងខ្ញុំសូមទទួលខុសត្រូវទាំងស្រុងសំរាប់ការបកប្រែពីប្រភពនានាក្នុងការធ្វើសំយោគនៅក្នុងតំបន់។

ខាងក្រោមនេះគឺជាបញ្ជីឈ្មោះនៃអ្នកស្រាវជ្រាវ REPSI ដែលបានរួមចំនែកនៅក្នុងករណីសិក្សាទាំងអស់។ ខេត្តញ៉ែ អាន វៀតណាមៈ Tran Duc Vien, Pham Thi Huong, Nguyen Thi Bich Yen, Nguyen Thi Phuong Mai, Dinh Hai Van, Nguyen Thu Ha សកលវិទ្យាល័យកសិកម្មក្រុងហាណូយ។ ខេត្តភូ ថូ វៀតណាមៈ Nguyen Quang Dung, កម្មវិធីអភិវឌ្ឍន៍ជនបទតំបន់ភ្នំវៀតណាម-ស៊ុយអែដ ; Do Thi Phuong Thao, ទីប្រឹក្សាឯករាជ្យ ;Bent Jørgensen និង Cecilia Bergstedt, សាកលវិទ្យាល័យគោធិនបើគ ខេត្តធួ ធៀនហួ វៀតណាមៈ Le Van An និង Le Quang Bao, សាកលវិទ្យាល័យកសិកម្មនិងរុក្ខាប្រមាញ់ Hue និង Malin Beckman, សាកលវិទ្យាល័យ វិទ្យាសាស្ត្រកសិកម្ម

ប្រទេសស៊ុយអែដ។ ខេត្តដា ឡាក់ វៀតណាម: Trinh Truong Giang, Hoang Huu Cai, Dang Tranh Ha, Vo Van Thoan, Le Quang Thong, Nguyen Duc Binh, Tran Van My, រាល់សាកលវិទ្យាល័យកសិកម្មនិងរុក្ខាប្រមាញ់ Thu Duc; and Alia Ahmad, វិទ្យាស្ថានណាតជីកសំរាប់ការសិក្សាអាស៊ី។ ខេត្តលួង ប្រាបាង ឡាវ: Sophab Khoungvichit, Sithong Thongmanivong, Boun Oum Siripoldej, Kaenchanh Sinsamphanh, Latsamy Chanthalangsy, និង Chanda Vongsombat រាល់សាកលវិទ្យាល័យជាតិនៃប្រទេសឡាវ។ ខេត្តរតនៈគីរី កម្ពុជា: Sith Sam Ath អ្នកស្រាវជ្រាវកម្ពុជាដើម្បីអភិវឌ្ឍន៍; Joankim Ojendal, Malin Hasselskog, and Mana Lilja, សាកលវិទ្យាល័យគោធិនបើគ; និង Pia Wallgren ទីប្រឹក្សាឯករាជ្យ។ ខេត្តយុន ណាន ចិន: Zuo Ting សាកលវិទ្យាល័យកសិកម្មចិន; Xu Jianchu; មជ្ឈមណ្ឌលសំរាប់ជីវសាស្ត្រចំរុះនិងចំណេះដឹងអន្តោគ្រាម និង Yang Yongping, វិទ្យាស្ថានយុនណាននៃវិទ្យាសាស្ត្រសង្គម។ ខេត្តឈៀងម៉ៃ ថៃ: Chanyuth Taepa អង្គការ CARE ប្រទេសថៃ; និង David Thomas, មជ្ឈមណ្ឌលអន្តរជាតិសំរាប់ការស្រាវជ្រាវកសិរុក្ខកម្ម (ICRAF) ។

យើងសូមថ្លែងអំណរគុណទៅដល់ធនធានមនុស្សដូចមាននៅខាងក្រោមនេះសំរាប់ការនែនាំនិងការគាំទ្ររបស់ពួកគេ: Frances Seymour និង Fredrich Kahrl, WRI និង David Thomas និងបុគ្គលិករបស់ ICRAF- ឈៀងម៉ៃ។ អរគុណផងដែរដល់អ្នកពិនិត្យកែសំរួលទាំងឡាយដែលនៅក្នុងមជ្ឈមណ្ឌលធនធានពិភពលោក (WRI) រួមមាន Anthony Janetos, Crescencia Maurer, Jesse Ribot, និង Patricia Zurita; និងអ្នកកែសំរួលដែលនៅខាងក្រៅ Jake Brunner, Jeff Fox, Mingsarn Kaosa-ard, និង Geraldine Zwack ។

ការងារទាំងនេះនឹងមិនអាចកើតចេញបានទេប្រសិនបើគ្មានជំនួយថវិការដ៏សប្បុរសនៃទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែដ(SIDA) ក្រសួងការបរទេសនៃរាជាណាចក្រហូឡង់ ក្រសួងការបរទេសនៃរាជាណាចក្រដាណឺម៉ាក, the Ford Foundation-Beijing និង the Rockefeller Foundation ។

# សេចក្តីដកស្រង់នៃការងារ

Agrawal, Arun និង Jesse C. Ribot, 1999, "ការទទួលខុសត្រូវនៅក្នុងការធ្វើវិមជ្ឈការៈក្របខ័ណ្ឌមួយនៃករណីសិក្សាអាស៊ីខាងត្បូងនិងអាហ្វ្រិចខាងលិច" ទិនានុប្បវត្តិនៃតំបន់អភិវឌ្ឍន៍ទាំងឡាយ ៣៣(៤):៤៧៣-៥០២។

Beckman, Malin, Le Van An, និង Le Quang Bao. 2002. ការរស់នៅជាមួយនិងទឹកជំនន់: ការប្រឈមមុខនិងយុទ្ធសាស្ត្រនៃការបន្សាំរបស់ក្រុមគ្រួសារនិងស្ថាប័នមូលដ្ឋាននានា នៅភូមិភាគកណ្ដាល វៀតណាម។ របាយការណ៍ SEI/REPSI លេខ៥ ទីក្រុងស្តុកខុម: វិទ្យាស្ថានបរិស្ថាននៃទីក្រុងស្តុកខុម។

Brettall, Anna. 2001. "ជំលោះបរិស្ថាននានានិងច្បាប់សេវាកម្មសាធារណៈ : អតីតនិង បច្ចុប្បន្ន" ឈុតនៃ បរិស្ថានប្រទេសចិន លេខ៤។

Crook, Richard C. and James Manor. 1998. ប្រជាធិបតេយ្យនិងការធ្វើវិមជ្ឈការនៅក្នុងតំបន់ អាស៊ីខាងត្បូងនិងអាហ្វ្រិចខាងលិច: ការចូលរួម ការទទួលខុសត្រូវនិងការអនុវត្តន៍ តួនាទី។ Cambridge: Cambridge University Press.

Jahiel, Abigail.1998. "អង្គការការពារបរិស្ថាននៅក្នុងប្រទេសចិន" ប្រឹត្តិបត្រ័ប្រចាំត្រីមាស ចិន លេខ១៥៦:៧៥៧-៧៨៧។

Jørgensen, Bent D., Cecilia Bergstedt, Nguyen Quang Dung, nig Do Thi Phuong Tha.2001. ដំណើរឡើងភ្នំមួយ:ការធ្វើវិមជ្ឈការនិង ការគ្រប់គ្រងធនធានធម្មជាតិនៅខេត្តភូថូ តំបន់ខ្ពង់រាបភាគខាងជើងនៃវៀតណាម។ របាយការណ៍ SEI/REPSI លេខ ៣ ទីក្រុង ស្តុកខុម: វិទ្យាស្ថានបរិស្ថាននៃទីក្រុងស្តុកខុម។

Mawhood, Philip.1983. រដ្ឋាភិបាលមូលដ្ឋាននៅប្រទេសកំពុងអភិវឌ្ឍន៍។ Chicester: John Wiley.

Öjendal, Joankim. Malin Hasselskog, Mona Lilja, Sith Sam Ath, Pia Wallgren.2001. ការផ្តោតទៅលើអនាធិបតេយ្យ: វិមជ្ឈការនិងការគ្រប់គ្រងធនធានធម្មជាតិនៅក្នុង ខេត្តរតនៈគីរី តំបន់ខ្ពង់រាបប្រទេសកម្ពុជា។របាយការណ៍ SEI/REPSI លេខ២ ទីក្រុង ស្តុកខុម: វិទ្យាស្ថានបរិស្ថាននៃទីក្រុងស្តុកខុម។

Oyugi, Walter O.200. "ការធ្វើវិមជ្ឈការសំរាប់អភិបាលកិច្ចល្អនិងការអភិវឌ្ឍន៍" កិច្ច ពិភាក្សាការអភិវឌ្ឍន៍តំបន់ ២១(១):៣-២២។

Wunsch, James S. និង Dele Olowu. 1995. ការបរាជ័យនៃរដ្ឋការមជ្ឈឹមៈ ស្ថាប័នទាំងឡាយ និងអភិបាលកិច្ចដោយខ្លួនឯងនៅអាហ្វ្រិច។ San Francisco: Institute for Contremporary Studies Press ។

សំរាប់គន្ថនិទ្ទេសដ៏ពេញលេញមួយ សូមមេត្តាមើលលើរបាយការណ៍ទាំងមូលនៃឯកសារនេះ។

[1] ប្រទេសភូមាគឺពុំបានបញ្ចូលក្នុងការសិក្សារបស់យើងនេះទេ តែទោះជាយ៉ាងណាការពិនិត្យពិច័យដ៏ពេញលេញមួយនៃតំបន់អាស៊ីអាគ្នេយ៍ដីគោកគួរតែបញ្ចូលប្រទេសភូមាផងដែរ។

[2] គឺផ្អែកទៅលើរបាយការណ៍ WRI ស្តីពី *បរិស្ថាន ជីវភាពរស់នៅនិងស្ថាប័នមូលដ្ឋានទាំងឡាយ* (៧៧ ទំព័រ)ដោយ Mairi Dupar និង Nathan Badenoch ជាមួយនិង Dang Thanh Ha, Hoang Huu Cai, Le Van An, Nguyen Quang Dung, Pham Thi Huong, Sith Sam Ath, Tran Duc Vien and Zuo Ting. វ៉ាស៊ីនតោន DC: វិទ្យាស្ថានធនធានពិភពលោក ២០០២។

[5] វាក៏បានបង្ហាញដោយ Robert Keohance នៅវិទ្យាស្ថានធនធានពិភពលោក២៣មករា២០០២។

[6] ដូចបានពណ៌នានៅក្នុងអក្សរសាស្ត្រដ៏ធំស្តីអំពីវិមជ្ឈការសារពើពន្ធរបស់ប្រទេសចិន ដែលជាសារធាតុមួយនៃកំណែទំរង់ដ៏ធំទូលាយ។ សំរាប់ការជ្រើសរើសឯកសារយោង សូមមើលវគ្គសេចក្តីដកស្រង់នៃការងារក្នុងឯកសារនេះ។

[8] ទំនាក់ទំនងជាបុគ្គលជាមួយ Mingsarn Kaosa-ard, កុម្ភៈ ២០០២។ មើលផងដែរទៅលើ The Economist, "រាល់វត្ថុដែលគួរពិចារណាៈ រដ្ឋធម្មនុញ្ញនៃប្រទេសថៃគ្របដណ្តប់ស្ទើរតែរាល់យថាភាព" និង "របៀបរបបថ្មីមួយៈ រដ្ឋធម្មនុញ្ញសតវត្សរ៍ទី១៦របស់ថៃផ្តល់នូវការនៃនាំដ៏ឥតខ្ចោះដើម្បីស្ថេរភាពនិងភាពរុងរឿង" ២មិនា២០០២។

[9] គំរោងកាត់បន្ថយភាពក្រីក្រនៃតំបន់ភ្នំនៅភាគខាងជើង ដែលសហការផ្តល់មូលនិធិដោយធនាគារពិភពលោកនិងក្រសួងកិច្ចការអភិវឌ្ឍន៍អន្តរជាតិនៃរាជាណាចក្រអង់គ្លេស(DFID), គឺជា"គំរោងវិមជ្ឈការពហុភាគីដើម្បីជួយដល់ប្រជាជនក្រីក្រនៅជនបទប្រហែល១លាននាក់(៨៥ភាគរយនៃប្រជាជនទាំងនេះគឺជាជនជាតិភាគតិច)នៅក្នុងតំបន់ដ៏ក្រីក្របំផុតរបស់វៀតណាម តាមរយៈការវិនិយោគទុនទានាទៅលើផ្លូវថ្នល់និងទីផ្សារ ធារាសាស្ត្រនិងការផ្គត់ផ្គង់ទឹក សុខភាពនិងការអប់រំជាមូលដ្ឋាននិងការអភិវឌ្ឍន៍សហគមន៍" សន្និសិទ្ធព័ត៌មានរបស់ធនាគារពិភពលោក "ប្រទេសវៀតណាមៈធនាគារពិភពលោកគូសបញ្ជាក់អំពីការគាំទ្រដោយអនុម័តគំរោងការកាត់បន្ថយភាពក្រីក្រថ្មី" No.2002/117/EAP, 25 October 2001.

[11] កិច្ចសំភាសន៍ជាមួយ Chanyuth Taepa, ៣០វិច្ឆិការ២០០១។

[12] កិច្ចសំភាសន៍ជាមួយ Chanyuth Taepa, ៣០វិច្ឆិការ២០០១។

[13] Souphab Khoungvichit, Sithong Thongmanivong, Nathan Badenoch et al., ការងារនៅមូលដ្ឋាន ខេត្តលួងប្រាបាង ខែវិច្ឆិការ២០០០។

[14] ការបង្ហាញដោយ Zuo Ting, REPSI សំនេរសំរាប់សិក្ខាសាលាស្តីពីវិមជ្ឈការ ខែកក្កដា២០០១ ខេត្តឈៀងម៉ៃ ប្រទេសថៃ។